ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## សម្រាប់ការចុះឈ្មោះបោះឆ្នោត
## ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

# មាតិកា

ទំព័រ

**មាតិកា** ..... ក

**អក្សរកាត់** ..... ង

**គោលបំណង** ..... ១

I. **ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត** ..... ២

១. ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការចុះឈ្មោះបោះឆ្នោត ..... ២

ក. ការិយាល័យចុះឈ្មោះបោះឆ្នោត ..... ២

ខ. ការិយាល័យបោះឆ្នោត ..... ២

គ. រយៈពេល និងពេលវេលានៃការចុះឈ្មោះបោះឆ្នោត ..... ២

ឃ. គំនូសតាងស្តីពីពេលវេលាសម្រាប់ការចុះឈ្មោះបោះឆ្នោត ..... ៤

២. ការបិទផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ..... ៤

៣. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់) ..... ៤

ក. បរិវេណខាងក្នុង ..... ៤

ខ. បរិវេណខាងក្រៅ ..... ៤

៤. វិធានការការពារសន្តិសុខនៅការិយាល័យចុះឈ្មោះបោះឆ្នោត ..... ៥

II. **ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់** ..... ៦

១. តួនាទី និងភារកិច្ចរបស់ កបឃ.ស ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ..... ៧

ក. ការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប ធ្វើប្រតិភូកម្មអំណាចឱ្យ ..... ៧

ខ. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការចុះឈ្មោះបោះឆ្នោត ..... ៨

២. តួនាទី និងភារកិច្ចរបស់ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ..... ៩

ក. តួនាទី និងភារកិច្ចរបស់ប្រធាន ក.ច.ប ..... ១០

ខ. តួនាទី និងភារកិច្ចរបស់អនុប្រធាន ក.ច.ប ..... ១១

គ. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ ..... ១២

ឃ. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ..... ១៣

ង. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាភារីកុំព្យូទ័រក្នុងឃុំ សង្កាត់ដែលមានភារីកុំព្យូទ័រលើសពីម្នាក់ ..... ១៤
ច. ក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព) ..... ១៤
III. ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត ..... ១៤
១. លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត ..... ១៤
២. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត ..... ១៥
៣. គំរូប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦ ..... ១៦
IV. ដំណើរប្រព្រឹត្តទៅនៃការចុះឈ្មោះបោះឆ្នោត ..... ២០
១. សម្ភារ និងបរិក្ខារសម្រាប់ការចុះឈ្មោះបោះឆ្នោត ..... ២០
២. ជំហានសង្ខេបនៃការចុះឈ្មោះបោះឆ្នោត ..... ២០
៣. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ..... ២៣
៤. ករណីអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះ ..... ២៥
ក. ករណីអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះ ..... ២៥
ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ហើយអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះ និងគ្មានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ ..... ២៦
៥. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឆ្នាំ២០១៦ ..... ២៧
ក. ករណីអ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឆ្នាំ២០១៦ តែបានប្តូរទីលំនៅក្នុងឃុំ សង្កាត់ ..... ២៧
ខ. ករណីអ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឆ្នាំ២០១៦ ក្នុងឃុំ សង្កាត់ផ្សេង ..... ២៨
៦. បែបបទ និងនីតិវិធីនៃការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ..... ២៨
៧. បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ..... ២៩
V. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ..... ២៩
១. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងនៅ កបឃ.ស ..... ៣០
២. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងនៅ គ.ជ.ប ..... ៣៣
៣. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ..... ៣៣
៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយបណ្តឹងក្នុងដំណាក់កាលនៃការចុះឈ្មោះ ..... ៣៤

VI. របាយការណ៍សរុបស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប ........ ៣៥

១. របាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ........ ៣៥

២. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យនីមួយៗ ........ ៣៥

៣. របាយការណ៍សរុបស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ........ ៣៦

៤. របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ........ ៣៧

៥. កញ្ចប់ដាក់គល់សៀវភៅសន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងកញ្ចប់ដាក់សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ........ ៣៧

ក. កញ្ចប់ដាក់គល់សៀវភៅសន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ........ ៣៨

ខ. កញ្ចប់ដាក់សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ........ ៣៨

៦. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប ........ ៣៩

ក. ការវេចខ្ចប់ស្បោង «ខ» ទី ១ ........ ៣៩

ខ. ការវេចខ្ចប់ស្បោង «ខ» ទី ២ និងស្បោង «ខ» បន្តបន្ទាប់ ........ ៤១

៧. ការបញ្ជូនស្បោង «ខ» ទៅ លធ.ខប ........ ៤២

៨. ការត្រួតពិនិត្យ និងការវេចខ្ចប់ស្បោង «ខ» នៅ លធ.ខប និងការវេចខ្ចប់ស្បោង «ខ» ដាក់ក្នុងស្បោង «គ» បញ្ជូនមក ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ........ ៤២

ក. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប ........ ៤៣

ខ. ការវេចខ្ចប់ស្បោង «គ» បញ្ជូនមក ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ........ ៤៥

៩. ការវេចខ្ចប់សម្ភារ ឯកសារផ្សេងៗទៀតដែលបានផ្គត់ផ្គង់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតបញ្ជូនមក គ.ជ.ប ........ ៤៦

VII. ការមិនផ្សាយបញ្ជីបោះឆ្នោតដំបូងជាសាធារណៈសម្រាប់គោលដៅនៃការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ........ ៤៧

១. ទីកន្លែងផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង ........ ៤៧

២. កាលបរិច្ឆេទនៃការផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង ........ ៤៧

VIII. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ........ ៤៨

១.ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ កបឃ.ស ........ ៤៨

ក. ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ........ ៤៩
ខ. ការទទួលពាក្យបណ្តឹង ........ ៤៩
គ. ការប្រជុំសម្រេចជាសាធារណៈ (រយៈពេល ០៣ ថ្ងៃ) ........ ៥០
២. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងនៅ គ.ជ.ប ........ ៥១
៣. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ........ ៥១
៤. ការបំពេញរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ គបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០) ........ ៥១
៥. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយបណ្តឹងក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ក្នុងការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ........ ៥២
ក. ករណីពាក្យបណ្តឹងតវ៉ា ........ ៥២
ខ. ករណីពាក្យបណ្តឹងជំទាស់ ........ ៥៣
៦. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ........ ៥៤
៧. ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបាត់បង់លក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងការស្រង់ឈ្មោះប្រជាពលរដ្ឋខ្មែរដែលត្រូវបំពេញលក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅក្រោយពេល គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ........ ៥៤
តារាងសង្ខេបទម្រង់បែបបទដែលត្រូវប្រើប្រាស់តាមលំដាប់ថ្នាក់ សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ........ ៥៦
តារកិច្ចសង្ខេបរបស់ក្រុមចុះឈ្មោះបោះឆ្នោត និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប្រចាំការ សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ........ ៥៧
ប្រតិទិននៃការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦ ........ ៥៩

# អក្សរកាត់

| | |
|---|---|
| គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ក្រុមចុះឈ្មោះបោះឆ្នោត | ក.ច.ប |
| ក្រុមចុះឈ្មោះបោះឆ្នោតពិសេស | ក.ច.ប.ព |
| ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ | ច.ប.ត.រ |
| បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ | ប.ន.ប.ថ |
| អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ឯកសារបញ្ជាក់អត្តសញ្ញាណ | ឯ.អ |
| នាយកដ្ឋាន | ន. |
| ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

អនុលោមតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ និងប្រតិទិននៃការចុះឈ្មោះបោះឆ្នោត ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ នេះត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលមានសិទ្ធិបោះឆ្នោត ត្រូវទៅបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ និងតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ គឺជាការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ដើម្បីបង្កើតបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ និងធ្វើជាមូលដ្ឋានក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនាឆ្នាំបន្តបន្ទាប់ទៀត។

សៀវភៅណែនាំនេះ មានគោលបំណងពន្យល់អំពីនីតិវិធីបច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍សំខាន់ៗនៃការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ តាមប្រព័ន្ធកុំព្យូទ័រ ដើម្បីឱ្យមន្ត្រីបោះឆ្នោត ពិសេស ក.ច.ប និង កបឃ.ស ទាំងអស់សិក្សាស្វែងយល់ និងអនុវត្តការងារតាមតួនាទីភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយលទ្ធផលល្អ។ សៀវភៅណែនាំនេះក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទីរបស់ខ្លួន ដើម្បីឱ្យការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦ នេះ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

# ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

## I. ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

### ១. ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការចុះឈ្មោះបោះឆ្នោត

#### ក. ការិយាល័យចុះឈ្មោះបោះឆ្នោត

ជាគោលការណ៍ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ហើយការិយាល័យចុះឈ្មោះបោះឆ្នោតផ្សេងទៀត ត្រូវមានទីតាំងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់។ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវរៀបចំឱ្យមានលក្ខណៈងាយស្រួលដល់ជនមានពិការភាពក្នុងការសុំចុះឈ្មោះ។

ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ គឺជាការិយាល័យចុះឈ្មោះបោះឆ្នោតចម្បង ដែលត្រូវបើកបម្រើការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៅពេលចាប់ផ្តើម និងពេលបញ្ចប់ដោយប្រើរយៈពេលប្រមាណមួយភាគពីរនៃរយៈពេលចុះឈ្មោះបោះឆ្នោតសរុប។

ការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅតាមភូមិមួយចំនួនក្រៅពីសាលាឃុំ សង្កាត់ត្រូវបើកបម្រើការចុះឈ្មោះបោះឆ្នោត ដោយប្រើពេលវេលាសរុបមិនឱ្យលើសពីមួយភាគពីរនៃរយៈពេលរួមដែលបានកំណត់ឡើយ។

#### ខ. ការិយាល័យបោះឆ្នោត

- ការិយាល័យបោះឆ្នោតមួយ ឬច្រើននឹងត្រូវបានបង្កើតឡើងក្នុងភូមិចំណុះឱ្យឃុំ សង្កាត់នីមួយៗទូទាំងប្រទេស ហើយការិយាល័យបោះឆ្នោតនីមួយៗត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន។
- ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនត្រឹម ៧៥០ (ប្រាំពីររយហាសិប) នាក់។ ប្រសិនបើការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់ គ.ជ.ប ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះទៅក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬការិយាល័យបោះឆ្នោតណាដែលជិតបំផុតនៅក្នុងឃុំ សង្កាត់ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងភូមិជាមួយតាមការចាំបាច់។

#### គ. រយៈពេល និងពេលវេលាសម្រាប់ការចុះឈ្មោះបោះឆ្នោត

- ការចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗមានរយៈពេល ៩០ ថ្ងៃ។
- ការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេសក្នុងថ្ងៃតែមួយ គឺថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ និងត្រូវបញ្ចប់នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦។
- នៅថ្ងៃចាប់ផ្តើមដំបូង ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់។

- ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃ គិតទាំងថ្ងៃសៅរ៍ទាំងថ្ងៃអាទិត្យ ពេលព្រឹកចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ដល់ម៉ោង ១១:៣០ (ដប់មួយ និងសាមសិប) នាទី និងពេលរសៀលពីម៉ោង ២:០០ (ពីរ) ដល់ម៉ោង ៥:៣០ (ប្រាំ និងសាមសិប) នាទីល្ងាច។ ក្នុងករណីមានអ្នកសុំចុះឈ្មោះបន្ត កបឃ.ស និង ក.ច.ប អាចបន្ថែមម៉ោងពេលនៃការចុះឈ្មោះបោះឆ្នោតតាមការជាក់ស្តែង ដោយជូនដំណឹងជាសាធារណៈដល់មេភូមិ ប្រជាពលរដ្ឋ ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍។
- ការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ ត្រូវបើកបម្រើការចុះឈ្មោះបោះឆ្នោតជាប់រហូតសម្រាប់រយៈពេលបានកំណត់ខាងលើ លើកលែងតែករណីប្រធានស័ក្តិ។ ក្នុងករណីនេះ ដោយមានការឯកភាពពី កបឃ.ស ក.ច.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈមន្ត្រី លធ.ខប ដើម្បីសុំការសម្រេចពី គ.ជ.ប។
- នៅក្នុងអំឡុងពេលនៃចុះឈ្មោះបោះឆ្នោត ក.ច.ប ត្រូវទទួលចុះឈ្មោះអ្នកសុំចុះឈ្មោះបោះឆ្នោត ដែលមកពីគ្រប់ភូមិក្នុងឃុំ សង្កាត់របស់ខ្លួន ទោះបីកំពុងធ្វើការចុះឈ្មោះបោះឆ្នោតនៅទីតាំងភូមិណាមួយក៏ដោយ។
- ក្នុងករណីដែលការចុះឈ្មោះបោះឆ្នោតមិនទាន់ផុតរយៈពេលកំណត់ ប៉ុន្តែការិយាល័យបោះឆ្នោតនីមួយៗ សុទ្ធតែបានចុះឈ្មោះបោះឆ្នោតគ្រប់ចំនួន ៧៥០ (ប្រាំពីររយហាសិប) នាក់ ហើយប្រសិនបើនៅតែមានអ្នកមកសុំចុះឈ្មោះបោះឆ្នោតទៀត ក.ច.ប ដោយមានការឯកភាពពី កបឃ.ស ត្រូវលើកសំណើជាបន្ទាន់ តាមរយៈ លធ.ខប មក គ.ជ.ប ដើម្បីបង្កើតការិយាល័យបោះឆ្នោតថ្មី។
- កបឃ.ស ត្រូវកំណត់ប្រតិទិននៃការចុះឈ្មោះបោះឆ្នោត សម្រាប់ការចុះឈ្មោះនៅតាមភូមិមួយចំនួនក្រៅពីការិយាល័យនៅសាលាឃុំ សង្កាត់ តាមសំណើរបស់ ក.ច.ប។ ក្នុងករណីនេះ ក.ច.ប ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយមេភូមិពាក់ព័ន្ធដើម្បីចាត់ចែងអនុវត្តការងារតាមប្រតិទិនដែលបានកំណត់ហើយ។ កបឃ.ស និង ក.ច.ប ត្រូវជូនដំណឹងទៅគ្រប់ភាគីពាក់ព័ន្ធអំពីការកំណត់ប្រតិទិននៃការចុះឈ្មោះបោះឆ្នោតនេះ។
- ក.ច.ប អាចកែសម្រួលកាលវិភាគនៃការចុះឈ្មោះបោះឆ្នោតតាមភូមិតាមការចាំបាច់ និងតាមសភាពជាក់ស្តែង ប៉ុន្តែត្រូវធានាថា រាល់ការកែសម្រួលត្រូវតែបានជូនដំណឹងជាសាធារណៈដល់មេភូមិ ប្រជាពលរដ្ឋ ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍។
- នៅតំបន់ ដែលប្រជាពលរដ្ឋខ្មែរពុំអាចមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោតនៅក្នុងម៉ោងធ្វើការធម្មតាបាន ដោយសារពួកគាត់ជាប់រវល់ធ្វើស្រែចម្ការ ឬធ្វើការងារនៅទីឆ្ងាយ ក.ច.ប ត្រូវសម្របសម្រួលម៉ោងធ្វើការប្រចាំថ្ងៃនៃការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យ

ប្រជាពលរដ្ឋខ្មែរទាំងនោះអាចមកចុះឈ្មោះបោះឆ្នោតបាន។ កបឃ.ស និង ក.ច.ប ត្រូវជូនដំណឹងដល់គ្រប់ភាគីពាក់ព័ន្ធអំពីការកែសម្រួលម៉ោងធ្វើការប្រចាំថ្ងៃរបស់ ក.ច.ប។

**ឃ.គំនូសតាងស្តីពីពេលវេលាសម្រាប់ការចុះឈ្មោះបោះឆ្នោត**

ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ ២០១៦ មានរយៈពេល ៩០ (កៅសិប) ថ្ងៃ តាមគំនូសតាងដូចខាងក្រោម៖




**ចំណាំ៖**

☛ ថ្ងៃទី៣០ ខែកញ្ញាដល់ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៦ ឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ។

**២. ការបិទផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត**

- កបឃ.ស ត្រូវបិទផ្សាយជាសាធារណៈនូវបញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងនៅទីតាំងមួយចំនួនក្នុងឃុំ សង្កាត់យ៉ាងតិច ១០ (ដប់) ថ្ងៃមុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត (បិទផ្សាយយ៉ាងយូរនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦)។
- កបឃ.ស និងប្រធាន ក.ច.ប ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេលកាលបរិច្ឆេទ និងប្រតិទិននៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន (នៅសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួន) ក្នុងរយៈពេលយ៉ាងតិច ០៣ (បី) ថ្ងៃមុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត។

**៣. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់)**

**ក. បរិវេណខាងក្នុង**

បរិវេណខាងក្នុងជាតំបន់ព័ទ្ធជុំវិញសំណង់ ឬអគារដែលការិយាល័យចុះឈ្មោះបោះឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយខ្សែវណ្ឌមណ្ឌលមួយដែលមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ និងច្រកចូលមួយ។

**ខ. បរិវេណខាងក្រៅ**

បរិវេណខាងក្រៅជាតំបន់ព័ទ្ធជុំវិញការិយាល័យចុះឈ្មោះបោះឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយខ្សែវណ្ឌមណ្ឌលមួយមានកាំប្រវែង ១០០ (មួយរយ)ម៉ែត្រ ឬតូចជាងអាស្រ័យ

ដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងវត្តអារាម សាលារៀន សាលមហោស្រព ឬទីធ្លាសាធារណៈជាដើម។

នៅតំបន់ទីប្រជុំជន បរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានកំណត់ដោយ កបឃ.ស ផ្អែកតាមស្ថានភាពជាក់ស្តែងនៃតំបន់នោះ។

## ៤. វិធានការការពារសន្តិសុខនៅការិយាល័យចុះឈ្មោះបោះឆ្នោត

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យទាំងនោះឱ្យជៀសផុតពីការរំខានអុកឡុក ការបំភិតបំភ័យ ការគំរាមកំហែង ឬអំពើហិង្សា និងរក្សាការពារ សម្ភារ បរិក្ខារ ឯកសារទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម៖

- ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារធាតុ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត លើកលែងតែក្នុងករណីមានការបង្កអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលក្នុងករណីនេះ គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប អាចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចបាន។ ក្នុងករណីមានសំណូមពរពី គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយនោះ ភ្នាក់ងារសន្តិសុខដែលមានបំពាក់អាវុធសមស្រប អាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធបាន។
- ហាមនាយ ឬពលនៃកងយោធពលខេមរភូមិន្ទ និងកងនគរបាលជាតិចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឬឈរជិតបរិវេណការពារសន្តិសុខ ប្រសិនបើពួកគាត់មិនទៅចុះឈ្មោះបោះឆ្នោត លើកលែងតែពួកគាត់ត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ និងត្រូវបាន គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ស្នើសុំអន្តរាគមន៍ ឬក្នុងករណីកើតមានគ្រោះថ្នាក់ផ្សេងៗដូចជាអគ្គិភ័យ ខ្យល់ព្យុះ ទឹកជំនន់ រញ្ជួយដី ជាដើម។
- ហាមជនគ្រប់រូបចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមធ្វើការ ឬក្រោយពេលការិយាល័យបិទទ្វារ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងបរិវេណខាងក្នុងនូវជនទាំងឡាយដូចខាងក្រោម៖

- ក.ច.ប ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោត ដែលបានទទួលការតែងតាំងពី គ.ជ.ប

- សមាជិក កបឃ.ស ដែលប្រចាំការពិនិត្យមើលដំណើរការប្រព្រឹត្តទៅនៃ ក.ច.ប ក្នុងការចុះឈ្មោះបោះឆ្នោត
- អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន ដែលទទួលស្គាល់ដោយ គ.ជ.ប
- ភ្នាក់ងារគណបក្សនយោបាយ ដែលទទួលបានការអនុញ្ញាតពី កបឃ.ស
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត និងមានបំណងចុះឈ្មោះ
- នីតិជនអមដំណើរអ្នកសុំចុះឈ្មោះជាជនមានពិការភាព ដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតបានដោយខ្លួនឯង
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែល គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប សំណូមពរក្នុងករណីចាំបាច់

សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវបានហាមឃាត់ នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅៈ

- ការស្លៀកពាក់ឯកសណ្ឋាន ឬការបិទផ្សាយស្លាកសញ្ញា ឬការនិយាយដែលមានការពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ។
- ការបង្ហាញការគាំទ្រ ឬការប្រឆាំងចំពោះគណបក្សនយោបាយណាមួយ។
- ការរារាំងប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬការរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ការបង្កការអុកឡុក ឬការរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត។

ជនគ្រប់រូប ដែលមានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ស្របតាមលក្ខខណ្ឌនៃច្បាប់បោះឆ្នោត និង ប.ន.ប.ថ។

សាលារៀន ទីវត្តអារាម និងរាល់សំណង់ អគារ សាល និងទីធ្លាសាធារណៈ ត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការរៀបចំជាការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោត។

## II. ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់

យោងតាមមាត្រា ៥០ នៃ ច.ប.ត.រ គ.ជ.ប ត្រូវធ្វើប្រតិភូកម្មអំណាចដល់ កបឃ.ស ឱ្យបំពេញតួនាទីជាតំណាងខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ។

## ១. តួនាទី និងភារកិច្ចរបស់ កបឃ.ស ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត

### ក. ការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានផ្ទេរប្រតិភូកម្មឱ្យ

ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត កបឃ.ស ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ជាជំនួយដល់ គ.ជ.ប តាមរយៈ លធ.ខប ក្នុងការកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត
- ជាជំនួយដល់ គ.ជ.ប តាមរយៈ លធ.ខប ក្នុងការផ្តល់ស្ថិតិប្រជាពលរដ្ឋខ្មែរ ឬដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត
- ត្រូវដឹកនាំ ក.ច.ប ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត និង ប.ន.ប.ថ
- ចាត់សមាជិក កបឃ.ស របស់ខ្លួន ០១ (មួយ) ទៅ ០២ (ពីរ) រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា ០៥ (ប្រាំ) រូប និង ០២ (ពីរ) ទៅ ០៣ (បី) រូប ចំពោះឃុំ សង្កាត់ណាដែលមានសមាជិកក្រុមប្រឹក្សាចាប់ពី ០៧ (ប្រាំពីរ) រូបឡើងទៅ ឱ្យប្រចាំការពិនិត្យមើលដំណើរការប្រព្រឹត្តទៅនៃ ក.ច.ប ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត។ ធានាឱ្យមានសមាសភាពពីគ្រប់គណបក្សនយោបាយដែលមានអាសនៈក្នុង កបឃ.ស ចូលរួមប្រចាំការពិនិត្យមើលដំណើរការប្រព្រឹត្តទៅនៃ ក.ច.ប ដើម្បីសម្របសម្រួល និងដោះស្រាយបញ្ហានានា ដែលបានកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សមាជិកដែលប្រចាំការនេះមិនទទួលប្រាក់កម្រៃបន្ថែមឡើយ
- ទទួលពាក្យស្នើសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ចូលរួមសង្កេតមើលការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ព្រមទាំងពិនិត្យសម្រេច និងចេញប័ណ្ណសម្គាល់ជូនភ្នាក់ងារគណបក្សនយោបាយតាមការណែនាំរបស់ គ.ជ.ប
- ទទួលបន្ទុកអប់រំផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ឱ្យទៅចុះឈ្មោះនៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់
- ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋខ្មែរកំពុងរស់នៅក្នុងឃុំ សង្កាត់ឱ្យទៅពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួននៅលើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតដែលបានបិទផ្សាយតាមកាលបរិច្ឆេទកំណត់ នៅសាលាឃុំ សង្កាត់ និងតាមទីតាំងណាមួយក្នុងឃុំ សង្កាត់ ដើម្បីបម្រើគោលដៅនៃការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់
- ធានាចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ឬលិខិតបញ្ជាក់ទីលំនៅជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ដែលបានស្នើសុំស្របតាមច្បាប់ដោយពុំមានតម្រូវឱ្យបង់សោហ៊ុយឡើយ។ ដើម្បីបម្រើគោលដៅនេះ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិអំណាចក្នុងការចេញឯកសារ និងលិខិតបញ្ជាក់ទាំងនេះ ត្រូវមានវត្តមាននៅសាលាឃុំ សង្កាត់ ឬត្រូវចុះ

ជាប់ជាមួយ ក.ច.ប ស្របពេលនឹងការចុះឈ្មោះបោះឆ្នោត នៅតាមទីតាំងការិយាល័យចុះឈ្មោះនៅសាលាឃុំ សង្កាត់ ឬចល័តតាមភូមិមួយចំនួន

- ទទួល និងដោះស្រាយរាល់បណ្ដឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយការប្រជុំជាសាធារណៈ
- ទទួល និងដោះស្រាយរាល់បណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ដោយការប្រជុំសម្រេចជាសាធារណៈ
- ទទួល និងដោះស្រាយបណ្ដឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូក ១០ នៃ ច.ប.ត.រ ប.ន.ប.ថ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនជាមន្ត្រីបោះឆ្នោត ឬ/និងជនមិនមែនជាមន្ត្រីបោះឆ្នោត ឬ/និងគណបក្សនយោបាយ ដែលអាចនាំឱ្យមានការពិន័យ (សៀវភៅណែនាំស្ដីពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយបណ្ដឹង)
- ផ្ញើជូន គ.ជ.ប នូវរាល់សេចក្ដីសម្រេចរបស់ខ្លួនដោះស្រាយលើបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ទ.១២០៣ និងផ្ដល់ទ.១២០២ សម្រាប់បំពេញបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់តាមសំណើសុំរបស់អ្នកប្ដឹង ឬតំណាង
- ផ្ដល់ជំនួយដល់ ក.ច.ប ក្នុងការផ្ទៀងផ្ទាត់ ការបូកសរុប ការរៀបចំវេចខ្ចប់ និងការបញ្ជូនលទ្ធផល និងសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតជូន គ.ជ.ប តាមរយៈ លធ.ខប
- ចាត់ចែងឱ្យមានកម្លាំងរក្សាសណ្ដាប់ធ្នាប់តាមលទ្ធភាព និងការចាំបាច់សម្រាប់សម្រួលដល់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។ ការចាត់ចែង ប្រើប្រាស់កម្លាំងរក្សាសណ្ដាប់ធ្នាប់នេះស្ថិតក្នុងសមត្ថកិច្ច និងបន្ទុកដោះស្រាយរបស់ កបឃ.ស
- ចាត់វិធានការសមស្របដើម្បីធានាថា រាល់កិច្ចប្រតិបត្តិការទាក់ទងដល់ការចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង។ ចាត់ចែងដោះស្រាយឱ្យមានអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងមានសមត្ថកិច្ច តាមសំណើរបស់ ក.ច.ប ក្នុងករណីដែលមានជនណាបង្កការអុកឡុក រំខាន គំរាមកំហែង ឬប្រព្រឹត្តអំពើល្មើសច្បាប់ សំដៅបង្អាក់ដំណាក់កាលណាមួយនៃការចុះឈ្មោះបោះឆ្នោត
- នៅពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោត ត្រូវសហការជាមួយ លធ.ខប ដើម្បីធ្វើការវាយតម្លៃចំពោះ ក.ច.ប តាមចំណុច ១.៧.៤ និង ១.៧.៥ នៃ ប.ន.ប.ថ រួចផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប។

**ខ. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការចុះឈ្មោះបោះឆ្នោត**

កបឃ.ស ត្រូវចាត់ចែងតាមលទ្ធភាព និងការចាំបាច់ឱ្យមានកម្លាំងរក្សាសណ្ដាប់ធ្នាប់ ដែលមានភារកិច្ចដូចខាងក្រោម៖

- សម្រួលសណ្តាប់ធ្នាប់សម្រាប់ប្រជាពលរដ្ឋ ដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោតដើម្បីសុំចុះឈ្មោះបោះឆ្នោត
- សម្រួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ០៣ (បី) នាក់ ឬច្រើនជាងនេះតាមចំនួនកាវីកុំព្យូទ័រ
- ផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាពចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- អនុញ្ញាតឱ្យអ្នកជំនួយជានីតិជនម្នាក់ ជូនដំណើរជនមានពិការភាពដែលមិនអាចចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- រាយការណ៍ជាបន្ទាន់ជូន កបឃ.ស ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ ឬច្រើននាក់ ដើម្បីមានវិធានការស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច។

## ២. តួនាទី និងភារកិច្ចរបស់ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)

អនុលោមតាមច្បាប់បោះឆ្នោត ប.ន.ប.ថ និងសេចក្តីសម្រេចផ្សេងៗទៀតដែលកំណត់ដោយ គ.ជ.ប ក.ច.ប ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោតត្រូវទទួលខុសត្រូវអនុវត្តរាល់កិច្ចប្រតិបត្តិការបម្រើឱ្យគោលបំណងនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្នុងការអនុវត្តភារកិច្ចនេះ ក.ច.ប ត្រូវៈ

- គោរពច្បាប់បោះឆ្នោត និង ប.ន.ប.ថ
- ប្រកាន់ជំហរឯករាជ្យ អព្យាក្រឹត និងមិនលម្អៀងក្នុងពេលបំពេញការងារ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការចុះឈ្មោះបោះឆ្នោត
- យល់ដឹងយ៉ាងច្បាស់លាស់ និងចេះម្ចាស់ការបានលើរាល់នីតិវិធីពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត
- ចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យក្នុងដំណើរការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព
- ចេះបំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗ ដែលបានកំណត់ ចេះធ្វើកុំព្យូទ័រកម្មទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោត និងចេះធ្វើរបាយការណ៍បានច្បាស់លាស់
- អនុវត្តតាមសេចក្តីសម្រេចរបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញក្នុងការចុះឈ្មោះបោះឆ្នោតជូនអ្នកសុំចុះឈ្មោះបោះឆ្នោត
- រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដែលទទួលបានក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត។

## ក. តួនាទី និងភារកិច្ចរបស់ប្រធាន ក.ច.ប

ប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើគំរូប្លង់ និងធានាថា ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ
- រៀបចំការិយាល័យចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាមពន្លឺដែលអាចឱ្យការីកុំព្យូទ័រនៃ ក.ច.ប អាចថតយករូបភាពអ្នកសុំចុះឈ្មោះបោះឆ្នោតបានច្បាស់ល្អ
- ត្រួតពិនិត្យ និងគ្រប់គ្រងបរិមាណ និងគុណភាព សម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត
- ត្រួតពិនិត្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានការបញ្ជាក់ទទួលស្គាល់រួចហើយ
- ត្រួតពិនិត្យ គ្រប់គ្រង និងអនុវត្តដោយផ្ទាល់នូវរាល់ដំណើរការ និងជំហាននៃការចុះឈ្មោះបោះឆ្នោត
- ទទួលធ្វើសម្ភាសន៍ និងពិនិត្យលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ព្រមទាំងធ្វើការសម្រេចអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត និងសម្រេចយល់ព្រម ឬបដិសេធការសុំចុះឈ្មោះបោះឆ្នោត។
- បំពេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះ
- ធានាថា បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ត្រូវបានរៀបចំតាមភូមិនីមួយៗក្នុងឃុំ សង្កាត់ និងធានាថាមានអ្នកបោះឆ្នោតមិនលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់
- ដោះស្រាយជាបន្ទាន់នូវរាល់ការតវ៉ា និងការជំទាស់ចំពោះការរំលោភច្បាប់នានានៅក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត
- ចូលរួមបំភ្លឺក្នុងរាល់ការប្រជុំសម្រេចរបស់ កបឃ.ស ដោះស្រាយបណ្តឹងតវ៉ា និងចាត់ការតាមការសម្រេចរបស់ កបឃ.ស និងតាមសមត្ថកិច្ចរបស់ខ្លួន
- ធានាថា ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានការបញ្ជាក់ទទួលស្គាល់ បានសង្កេតមើលដំណើរការនៃការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់
- ស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬអាជ្ញាធរមានសមត្ថកិច្ចឱ្យនាំខ្លួនជនទាំងឡាយណាដែលបង្កការអុកឡុករំខាន ឬធ្វើសកម្មភាពផ្ទុយពីការកំណត់របស់ច្បាប់បោះឆ្នោត ឬ ប.ន.ប.ថ ក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត
- សំណូមពរភ្នាក់ងារសង្គ្រោះ ឱ្យជួយដល់ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាព ឬជនទាំងឡាយណាដែលទទួលរងគ្រោះដោយមូលហេតុណាមួយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត

- រាយការណ៍ជូន គ.ជ.ប តាមរយៈ កបឃ.ស និង លធ.ខប នូវរាល់ហេតុការណ៍ដែលអាចកើតមានក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីសម្របសម្រួលដោះស្រាយបញ្ហា
- អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ព្រមទាំង ប.ន.ប.ថ របស់ គ.ជ.ប។

**ខ. តួនាទី និងភារកិច្ចរបស់អនុប្រធាន ក.ច.ប**

អនុប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជួយប្រធានក្នុងការធ្វើគំរូប្លង់ និងធានាថាការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ
- ជួយប្រធានក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងបរិមាណ និងគុណភាពសម្ភារបរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត
- ថែរក្សាសុវត្ថិភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត
- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) កំណត់ការិយាល័យបោះឆ្នោត ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា និងបោះត្រាបន្ថែមនៅលើ ទ.១០២២ រវាងគល់ទម្រង់ និងបង្កាន់ដៃ រួចប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឱ្យទៅការីកុំព្យូទ័រ
- បំពេញទម្រង់បង្កាន់ដៃទទួលការប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់(ទ.១០២៨) ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា និងបោះត្រាបន្ថែមនៅលើ ទ.១០២៨ រវាងគល់ទម្រង់ និងបង្កាន់ដៃ បន្ទាប់មកឱ្យអ្នកស្នើសុំផ្តិតមេដៃ និងសរសេរឈ្មោះ រួចហែកបង្កាន់ដៃជូនការីកុំព្យូទ័រ ព្រមទាំងដកហូតបង្កាន់ដៃ ទ.១០២២ ចាស់ កិបភ្ជាប់ជាមួយគល់ ទ.១០២៨ ដែលត្រូវបញ្ជូនមក គ.ជ.ប
- ថែរក្សាទុកជាឯកសារនូវរាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) រាល់សម្រង់សេចក្តីសម្រេចដោះស្រាយលើបណ្តឹងតវ៉ា ឬ/និង បណ្តឹងជំទាស់ (ទ.១២០៣) ដែលចេញដោយ កបឃ.ស និងឯកសារពាក់ព័ន្ធផ្សេងទៀតមួយមុខមួយច្បាប់ៗ
- រួមជាមួយសមាជិកដែលជាការីកុំព្យូទ័រ បញ្ជូនទិន្នន័យអ្នកបោះឆ្នោតដែលបានបញ្ចូលក្នុងកុំព្យូទ័ររួច តាមប្រព័ន្ធអ៊ីនធឺណិតជារៀងរាល់ថ្ងៃ ឬតាមរយៈគ្រូប្រចាំស្រុក ករណីគ្មានសេវាអ៊ីនធឺណិតទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតាមភូមិទាំងអស់ក្នុងឃុំ សង្កាត់

- ផ្ញើរបាយការណ៍ផ្ទៀងផ្ទាត់លទ្ធផលនៃការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ (ទ.១០២៩) និងរបាយការណ៍សរុបចុងក្រោយសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ (ទ.១០១១) និងសម្រាប់ឃុំ សង្កាត់ទាំងមូលនៅពេលដែលការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់
- ធានាក្នុងការផ្ទៀងផ្ទាត់ការវេចខ្ចប់ដោយឡែក តាមការិយាល័យបោះឆ្នោតនីមួយៗ នូវរាល់ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះ និងការប្តឹងតវ៉ា ព្រមទាំងគល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលបានប្រើហើយ និងទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើ និងសម្ភារ ឯកសារនៅសល់ផ្សេងទៀតជូន លធ.ខប
- រួមជាមួយប្រធានចូលរួមបំភ្លឺក្នុងរាល់ការប្រជុំសម្រេចរបស់ កបឃ.ស ដោះស្រាយពាក្យបណ្តឹងតវ៉ា
- អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ព្រមទាំង ប.ន.ប.ថ របស់ គ.ជ.ប។

### គ. តួនាទី និងភារកិច្ចរបស់សមាជិក គ.ច.ប ដែលជាការីកុំព្យូទ័រ

តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ រួមមាន៖

- ជួយប្រធានក្នុងការធ្វើគំរូប្លង់ និងធានាថា ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ
- ជួយប្រធានក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងបរិមាណ និងគុណភាពសម្ភារបរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត
- ជួយអនុប្រធានក្នុងការថែរក្សាសុវត្ថិភាពសម្ភារ បរិក្ខារ ឯកសារចុះឈ្មោះបោះឆ្នោត មុនពេលចាប់ផ្តើមការចុះឈ្មោះបោះឆ្នោត និងបន្តពិនិត្យតាមដាននៅពេលបញ្ឈប់ការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃនីមួយៗ
- ម្ចាស់ការក្នុងការដំឡើងកុំព្យូទ័រ និងបរិក្ខារបំពាក់ រួមនឹងប្រព័ន្ធអ៊ីនធឺណិតសម្រាប់ដំណើរការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ
- ជ្រើសរើសយកឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាង ថត អ.ខ ឬ ឯ.អ បញ្ចូលលេខ អ.ខ ឬ ឯ.អ បញ្ចូលអត្តលេខអ្នកបោះឆ្នោតដែលមានក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ និងបញ្ចូលទិន្នន័យតាមកម្មវិធីដែលបានរៀបចំរួចក្នុងប្រព័ន្ធកុំព្យូទ័រ
- ផ្ទេរឈ្មោះ និងទិន្នន័យអ្នកសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទៅការិយាល័យបោះឆ្នោតថ្មីក្នុងភូមិដែលគាត់រស់នៅ តាមការកំណត់របស់អនុប្រធាន ក.ច.ប

- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើម៉ាស៊ីនស្កេន ដើម្បីយកស្នាមមេដៃទាំងសងខាងនៃអ្នកសុំចុះឈ្មោះបោះឆ្នោត ថតរូប និងថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន) បញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដែលរក្សាទុក ក្នុងប្រព័ន្ធកុំព្យូទ័ររួចហើយ ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ និង អ.ខ ឬ ឯ.អ ដល់អ្នកសុំចុះឈ្មោះវិញ
- រួមជាមួយអនុប្រធានចាត់ចែងបញ្ជូនទិន្នន័យអ្នកបោះឆ្នោត ដែលបានបញ្ចូលក្នុងកុំព្យូទ័ររួច តាមប្រព័ន្ធអ៊ីនធឺណិតជារៀងរាល់ថ្ងៃទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតាមភូមិទាំងអស់ក្នុងឃុំ សង្កាត់
- ជួយអនុប្រធានក្នុងការធ្វើរបាយការណ៍ ផ្ទៀងផ្ទាត់លទ្ធផលនៃការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ និងរបាយការណ៍សរុបចុងក្រោយសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ និងសម្រាប់ឃុំ សង្កាត់ទាំងមូល នៅពេលដែលការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់
- ជួយអនុប្រធានក្នុងការផ្ទៀងផ្ទាត់ ការវេចខ្ចប់កញ្ចប់ «ក» ស្បោង «ខ» និងរាល់សម្ភារ ឯកសារផ្សេងទៀតជូន លធ.ខប
- ជួយអនុប្រធានក្នុងការផ្ទៀងផ្ទាត់ ការវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗនូវរាល់ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត និងការប្ដឹងតវ៉ា ព្រមទាំងគល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយ ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើ និងសម្ភារ ឯកសារនៅសល់ផ្សេងទៀតជូន លធ.ខប
- អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ព្រមទាំង ប.ន.ប.ថ របស់ គ.ជ.ប។

**ឃ.តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប**

តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជួយការងារអនុប្រធានក្រុម រួមមាន៖

- ជួយការងារអនុប្រធាន ក.ច.ប ក្នុងការរៀបចំដំណើរការចុះឈ្មោះបោះឆ្នោត
- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត កំណត់ការិយាល័យបោះឆ្នោត ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា និងបោះត្រាបន្ថែមនៅលើ ទ.១០២២ រវាងគល់ទម្រង់ និងបង្កាន់ដៃ រួចប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឱ្យទៅការីកុំព្យូទ័រ
- បំពេញទម្រង់បង្កាន់ដៃទទួលការប្ដូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០២៨) ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា និងបោះត្រាបន្ថែមនៅលើ ទ.១០២៨ រវាងគល់ទម្រង់ និងបង្កាន់ដៃ បន្ទាប់មកឱ្យអ្នកស្នើសុំផ្ដិតមេដៃ និងសរសេរ

ឈ្មោះ រួចហែកបង្កាន់ដៃជូនការីកុំព្យូទ័រ ព្រមទាំងដកហូតបង្កាន់ដៃ ទ.១០២២ ចាស់ កិបភ្ជាប់ជាមួយគល់ ទ.១០២៨ ដែលត្រូវបញ្ជូនមក គ.ជ.ប

- អនុវត្តការងារដទៃទៀត ដែលប្រធាន ឬអនុប្រធានប្រគល់ឱ្យ។

**ង. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ ក្នុងឃុំ សង្កាត់ដែលមានការីកុំព្យូទ័រលើសពីម្នាក់**

តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ ក្នុងឃុំ សង្កាត់ដែលមានការីកុំព្យូទ័រលើសពីម្នាក់ ដូចគ្នានឹងតួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ។

**ច. ក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព)**

ក្រោយពេល ក.ច.ប ត្រូវបានរំសាយ ដើម្បីអនុវត្តសេចក្តីសម្រេចយល់ព្រមរបស់ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ លើបណ្តឹងតវ៉ាទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត និងសេចក្តីសម្រេចយល់ព្រមរបស់ កបឃ.ស គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ លើបណ្តឹងតវ៉ាទៅនឹងបញ្ជីបោះឆ្នោតដំបូង គ.ជ.ប ត្រូវចាត់តាំងក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព) ដើម្បីចុះឈ្មោះអ្នកប្តឹងតវ៉ាដែលត្រូវបានយល់ព្រមឱ្យចុះឈ្មោះក្នុងបញ្ជីបោះឆ្នោត។

- ក.ច.ប.ព មានសមាសភាពប្រធាន ០១ (មួយ) រូប សមាជិក ០១ (មួយ) រូបជាមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប និងអនុប្រធានជាស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ។
- ក.ច.ប.ព ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោតដូចចែងក្នុងជំហានទាំងបួននៃការចុះឈ្មោះបោះឆ្នោត។
- បន្ទាប់ពីបញ្ចប់ការចុះឈ្មោះបោះឆ្នោត ទិន្នន័យអ្នកបោះឆ្នោតត្រូវបញ្ជូនតាមអ៊ីនធឺណិតទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត។
- ក.ច.ប.ព មានអាណត្តិបំពេញការងារតាមការកំណត់របស់ គ.ជ.ប។

## III. ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត

### ១. លក្ខខណ្ឌដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។

ដើម្បីចុះឈ្មោះបោះឆ្នោតប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវបង្ហាញខ្លួន និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅចំពោះមុខ ក.ច.ប ដែលទទួលបន្ទុកជាមន្ត្រីចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត (កើតមុន ឬត្រឹមថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ១៩៩៩)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត

- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច
- មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយក្នុងឆ្នាំ២០១៦ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

**ចំណាំ៖**

- ប្រជាពលរដ្ឋខ្មែរម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់។ ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀលទៅ ១០០.០០០ (មួយសែន) រៀលដោយ គ.ជ.ប ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ។
- ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬទីសំណាក់ច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់ខ្លួន ដើម្បីចុះឈ្មោះបោះឆ្នោត។
- ប្រជាពលរដ្ឋខ្មែរ ឬកម្មករ និយោជិត សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នាយ ឬពលនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ និងបព្វជិតសាសនាដែលកំពុងស្នាក់នៅក្នុងឃុំ សង្កាត់ណាមួយសុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះបានឱ្យតែសាមីខ្លួនបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។

## ២.ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត

ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត គឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬអស់សុពលភាពទាំង ០៣ ប្រភេទ ដូចខាងក្រោម។

**អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ**




ឬ




ឬ



៣. គំរូប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦



## គំរូប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦

ខ- សម្រាប់ការិយាល័យដែលមានមន្ត្រីចុះឈ្មោះចំនួន ៥ នាក់ ៖




ប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោត
ត្រូវរៀបចំដោយផ្អែកតាមពន្លឺដែលអាចឱ្យការីកុំព្យូទ័រនៃ គ.ច.ប
អាចថតយករូបភាពអ្នកសុំចុះឈ្មោះបោះឆ្នោតបានច្បាស់ល្អ

## ផ្ទាំងប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦

ឥ- សម្រាប់ការិយាល័យដែលមានមន្ត្រីចុះឈ្មោះចំនួន ៩ នាក់ (បើលើសពី ៩ នាក់ ត្រូវរៀបចំតាមស្ថានភាពជាក់ស្ដែងនៃការិយាល័យនីមួយៗ)៖




ប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោត
ត្រូវរៀបចំដោយផ្អែកតាមពន្លឺដែលអាចឱ្យការីកុំព្យូទ័រនៃ គ.ជ.ប
អាចថតយករូបភាពអ្នកសុំចុះឈ្មោះបោះឆ្នោតបានច្បាស់ល្អ


គំរូការិយាល័យចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦
គ.ជ.ប
ក្រុមប្រឹក្សាឃុំ សង្កាត់
ច្រកចូល
ច្រកចេញ
ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍
ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍
ភ្នាក់ងារគណបក្ស និងអ្នកសង្កេតការណ៍
សូមអញ្ជើញប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ឬនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ដល់ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦

## IV. ដំណើរប្រព្រឹត្តទៅនៃការចុះឈ្មោះបោះឆ្នោត

កបឃ.ស ស្មៀនឃុំ សង្កាត់ មេភូមិ និង ក.ច.ប ត្រូវជួយផ្សព្វផ្សាយបំផុស និងលើកទឹកចិត្តប្រជាពលរដ្ឋទូទៅដែលមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោតឱ្យមកចុះឈ្មោះបោះឆ្នោត។ អ្នកមកចុះឈ្មោះបោះឆ្នោត គឺជា ៖

- ប្រជាពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ ដែលមានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត (កើតមុន ឬត្រឹមថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៩)
- ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ និងអ្នកពុំធ្លាប់បានចុះឈ្មោះបោះឆ្នោត
- ប្រជាពលរដ្ឋខ្មែរដែលបានផ្លាស់ទីលំនៅចូលពីឃុំ សង្កាត់ផ្សេង ទោះបីធ្លាប់បានចុះឈ្មោះ ឬមិនធ្លាប់បានចុះឈ្មោះបោះឆ្នោតក៏ដោយ។

### ១. សម្ភារ និងបរិក្ខារសម្រាប់ការចុះឈ្មោះបោះឆ្នោត

សម្ភារ និងបរិក្ខារសម្រាប់ការចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ និងបញ្ជូនទិន្នន័យពីឃុំ សង្កាត់ទៅ គ.ជ.ប តាមប្រព័ន្ធអ៊ីនធឺណិត រួមមាន៖

- កុំព្យូទ័រ (Laptop) ចំនួន ០១ (មួយ) គ្រឿង
- មៅ (Mouse)
- ម៉ូនីទ័រ (Monitor) ចំនួន ០១ (មួយ)
- ម៉ាស៊ីនស្កែនស្នាមម្រាមដៃចំនួន ០១ (មួយ) គ្រឿង
- USB Webcam Camera ថតរូប ចំនួន ០១ (មួយ) គ្រឿង
- ផ្ទាំងកំណាត់ផ្ទៃពណ៌ប្រផេះមួយផ្ទាំងសម្រាប់ធ្វើផ្ទៃថតរូប
- USB Flash Drive ចំនួន ០២ (ពីរ)
- Switch សម្រាប់ ក.ច.ប មានកុំព្យូទ័រចាប់ពី ០៣ (បី) គ្រឿងឡើង
- ឧបករណ៍ផ្ទុកថាមពល (Power Bank) ចំនួន ០១ (មួយ)
- ម៉ាស៊ីនភ្លើងមួយគ្រឿង (សម្រាប់ឃុំ សង្កាត់គ្មានចរន្តអគ្គិសនី)
- 3G Modem ចំនួន ០១ (មួយ) ប្រើ SIM Card (បីបណ្តាញ)
- SD Card ចំនួន ០១ (មួយ)
- ជើងទម្រម៉ាស៊ីនថតរូប (Camera Stand) ចំនួន ០១ (មួយ)

### ២. ជំហានសង្ខេបនៃការចុះឈ្មោះបោះឆ្នោត

ដើម្បីចុះឈ្មោះបោះឆ្នោត ក.ច.ប ត្រូវអនុវត្តតាមនីតិវិធីដូចបញ្ជាក់ក្នុងជំហានទាំង ៤ ខាងក្រោម៖

- **ជំហានទី ១**

ប្រធាន ក.ច.ប ត្រូវ៖

- ធ្វើសម្ភាសន៍អ្នកសុំចុះឈ្មោះបោះឆ្នោត។
- សាកសួរព័ត៌មានគាត់ថា៖
  - តើអ្នកមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ឬទេ?
  - តើអ្នកបានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ ឬនៅ?

- **ជំហានទី ២**

ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងមិនទាន់បានចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ប្រធាន ក.ច.ប ត្រូវ៖

- ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះដូចខាងក្រោម៖
  - ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
  - មានអាយុ ១៨ ឆ្នាំ ឡើងទៅគិតដល់ថ្ងៃបោះឆ្នោត (កើតមុន ឬត្រឹមថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ១៩៩៩)
  - មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន ក.ច.ប ដើម្បីបន្តនីតិវិធីចុះឈ្មោះបោះឆ្នោតតាមជំហានបន្តបន្ទាប់ (ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញគ្រប់លក្ខខណ្ឌកំណត់)។

ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ប្រធាន ក.ច.ប ត្រូវ៖

បដិសេធការសុំចុះឈ្មោះ ដោយទម្រង់បែបបទបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់ពីមូលហេតុ និងលក្ខខណ្ឌ ដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ។

- **ជំហានទី ៣**

អនុប្រធាន ក.ច.ប ឬសមាជិកដែលជួយការងារអនុប្រធាន ត្រូវ៖

- សួរទីលំនៅ នៅភូមិណាដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោតក្នុងភូមិនោះ។
- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា និងបោះត្រាបន្ថែមនៅលើ ទ.១០២២ រវាងគល់ទម្រង់ និងបង្កាន់ដៃ។
- ប្រគល់ អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ និងបង្កាន់ដៃ ទ.១០២២ ទៅការីកុំព្យូទ័រ និងជម្រាបអ្នកសុំចុះឈ្មោះនោះឱ្យទៅជួបការីកុំព្យូទ័រ។

- ជំហានទី ៤

ការីកុំព្យូទ័រត្រូវ៖

- កត់ត្រាទិន្នន័យអ្នកសុំចុះឈ្មោះទៅក្នុងប្រព័ន្ធកុំព្យូទ័រដោយផ្អែកតាម អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម៖
  - ជ្រើសយកឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតតាម ទ.១០២២
  - ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតជាមុន បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាង។ ចំពោះអ្នកពិការដៃម្ខាង ឬទាំងសងខាង ឬគ្មានស្នាមម្រាមដៃ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់ដំណើរការកម្មវិធី
  - ថត អ.ខ ឬ ឯ.អ
  - ជ្រើសរើសយកប្រភេទឯកសារសម្រាប់ប្រើចុះឈ្មោះបោះឆ្នោត (អ.ខ ឬ ឯ.អ)
  - បញ្ចូលលេខ អ.ខ ឬ ឯ.អ
  - បញ្ចូលអត្តលេខ អ្នកសុំចុះឈ្មោះដែលមាននៅក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត
  - បញ្ចូលនាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត
  - បញ្ចូលលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់របស់សាមីខ្លួន។
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើម៉ាស៊ីនស្កែន ដើម្បីយកស្នាមមេដៃសាមីខ្លួនទាំងសងខាងឆ្វេងចំនួន ០៤ ដង និងស្តាំចំនួន ០៤ ដង បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដោយត្រូវយកស្នាមមេដៃឆ្វេងមុន។ ក្នុងករណីអ្នកសុំចុះឈ្មោះពិការមេដៃណាមួយ ឬទាំងសងខាងត្រូវយកស្នាមម្រាមដៃបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះពិការដៃម្ខាង ត្រូវយកស្នាមមេដៃម្ខាងដែលមាន។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ត្រូវធ្វើការកត់ត្រាចូលក្នុងរបាយការណ៍ជូន គ.ជ.ប។
- ថតរូបចំពីមុខ និងថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន)។ ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ការីកុំព្យូទ័រត្រូវថតយក ដូចខាងក្រោម៖
  - ថតយកសន្លឹកទី ២ ដែលបញ្ជាក់ពីលំនៅឋាន សម្រាប់សៀវភៅគ្រួសារ
  - ថតយកសន្លឹកទី ១ ដែលបញ្ជាក់ពីលំនៅឋាន សម្រាប់សៀវភៅស្នាក់នៅ
  - ថតយកទម្រង់ទាំងមូល សម្រាប់លិខិតបញ្ជាក់ទីលំនៅ។
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យគាត់ផ្ទៀតផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ។ ករណីអ្នកសុំចុះឈ្មោះមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យរបស់គាត់។
- រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ។
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និង អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

**ចំណាំ៖**

- ការីកុំព្យូទ័រត្រូវបើកប្រព័ន្ធអ៊ីនធឺណិត (ករណីមានប្រព័ន្ធអ៊ីនធឺណិត) ដើម្បីបញ្ជូនទិន្នន័យទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតតាមរបៀបដូចខាងក្រោម៖
  - ដើម្បីទទួលបានប្រសិទ្ធភាព ការបញ្ជូនទិន្នន័យអាចធ្វើការបញ្ជូនម្តងចំនួន ១០ នាក់ក្នុងពេលទំនេរណាមួយ ដែលពុំមានប្រជាពលរដ្ឋមកសុំចុះឈ្មោះ ឬក្នុងម៉ោងឈប់សម្រាករហូតដល់អស់ទិន្នន័យ លើកលែងតែឃុំ សង្កាត់ណាដែលមានប្រព័ន្ធសេវាអ៊ីនធឺណិតខ្លាំងអាចធ្វើការបញ្ជូនលើសពីចំនួន ១០ នាក់ តាមលទ្ធភាពដែលអាចធ្វើបាន។
  - សម្រាប់ឃុំ សង្កាត់គ្មានប្រព័ន្ធអ៊ីនធឺណិត គ្រូតាមស្រុក គឺជាអ្នកសម្របសម្រួលជាមួយ ក.ច.ប ក្នុងការប្រមូលទិន្នន័យ (File Backup) ដែលត្រូវរក្សាទុកក្នុងហ្វ្លាស (Flash) មានបង្កប់លេខសម្ងាត់ មិនអាចបើកមើល ឬកែទិន្នន័យទាំងនោះបាន ទៅតំបន់ដែលមានប្រព័ន្ធអ៊ីនធឺណិតដើម្បីបញ្ជូនទិន្នន័យទាំងនោះទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។
- នៅរៀងរាល់ថ្ងៃ ពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោតតាមថ្ងៃនីមួយៗ អនុប្រធាន និងការីកុំព្យូទ័រ ត្រូវត្រួតពិនិត្យឱ្យប្រាកដថា លទ្ធផលនៃការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃត្រូវបានបញ្ជូនតាមប្រព័ន្ធអ៊ីនធឺណិតទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតរួចរាល់ហើយ។
- នៅពេលផ្ទៀងផ្ទាត់ ត្រូវប្រៀបធៀបចំនួនសរុបនៃបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងចំនួនទិន្នន័យសរុបដែលបានបញ្ជូន។
- បន្ទាប់មក ត្រូវបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) ចំនួន ០២ (ពីរ) ច្បាប់ ព្រមទាំងបិទផ្សាយរបាយការណ៍នេះ នៅមុខការិយាល័យចុះឈ្មោះបោះឆ្នោតចំនួន ០១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ០១ (មួយ) ច្បាប់។

**៣. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** (អ.ខ)

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់គ្មាន អ.ខ ប្រធាន ក.ច.ប ត្រូវចេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះ (ទ.១០០៩) ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ និងណែនាំថា៖

- សូមអ្នកទៅបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ ដែលអ្នកត្រូវចុះឈ្មោះ ដោយនាំយកមកជាមួយនូវសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើតច្បាប់ដើម ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរតាមការទាមទារសញ្ជាតិខ្មែររបស់ជនបរទេស ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់ជន

បរទេស ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា សាមីខ្លួននោះកើតពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ ឬឯកសារភស្តុតាងផ្លូវការដែលបញ្ជាក់ថា សាមីខ្លួនកើតមកពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ និងនាំសាក្សី ០២ រូប ដែលមានសិទ្ធិបោះឆ្នោត មានលំនៅឋាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់ទៅជាមួយ រួមជាមួយរូបថតសាមីខ្លួន ទំហំ ៣×៤ ចំនួន ០២ សន្លឹក ដើម្បីអាជ្ញាធរឃុំ សង្កាត់ បំពេញបែបបទផ្ដល់ ឯ.អ ជូន។

- ប្រសិនបើអ្នកទទួលបាន ឯ.អ នៅក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួបក្រុមចុះឈ្មោះវិញ ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត។

**លិខិតស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតស្នើសុំ**

**ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត** ៤៧៨៧

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ.......... សញ្ជាតិ.......... កើតនៅថ្ងៃទី.......... ខែ.......... ឆ្នាំ..........
មានលំនៅឋាន ឬទីសំណាក់លេខ ....................ផ្លូវ....................ភូមិ........................ឃុំ សង្កាត់ ....................
ក្រុង ស្រុក ខណ្ឌ ..........................រាជធានី ខេត្ត................................ ។

**រួមនឹងសាក្សី**

ឈ្មោះ...............................ភេទ.......... សញ្ជាតិ.......... កើតនៅថ្ងៃទី.......... ខែ.......... ឆ្នាំ.......... និង
ឈ្មោះ...............................ភេទ.......... សញ្ជាតិ.......... កើតនៅថ្ងៃទី.......... ខែ.......... ឆ្នាំ..........
ដែលមានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយ ដែលធានាថា ពិតជាស្គាល់ខ្ញុំបាទ/នាងខ្ញុំប្រាកដមែន និងទទួលខុសត្រូវតាមច្បាប់ជាធរមាន ចំពោះការធានានេះ ។

**គោរពជូន**

លោក លោកស្រីមេឃុំ ចៅសង្កាត់ ..........................................

កម្មវត្ថុ : សំណើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។

សេចក្ដីដូចបានជម្រាបជូនខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាបលោក លោកស្រីមេឃុំ ចៅសង្កាត់ថា នៅពេលចុះឈ្មោះបោះឆ្នោត ខ្ញុំបាទ/នាងខ្ញុំ មិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ☐ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្ញុំបាទ/នាងខ្ញុំ បានបាត់ ឬខូច ☐ ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេឃុំ ចៅសង្កាត់ ចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតឱ្យ ខ្ញុំបាទ/នាងខ្ញុំ ដោយអនុគ្រោះ ។

..............ថ្ងៃទី.......... ខែ.......... ឆ្នាំ..........

ស្នាមមេដៃសាក្សីទី ១ ស្នាមមេដៃសាក្សីទី ២ ស្នាមមេដៃអ្នកស្នើសុំ

ឈ្មោះ.......................... ឈ្មោះ.......................... ឈ្មោះ..........................

**ចំណាំ:** - ត្រូវបង្ហាញជូនលោក លោកស្រីមេឃុំ ចៅសង្កាត់នូវ សំបុត្រកំណើតច្បាប់ដើម ឬសេចក្ដីចម្លងសំបុត្រកំណើតច្បាប់ដើម ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬព្រះរាជក្រឹត្យផ្ដល់សញ្ជាតិខ្មែរតាមការទាមទារសញ្ជាតិខ្មែររបស់ជនបរទេស ឬព្រះរាជក្រឹត្យផ្ដល់សញ្ជាតិដោយសញ្ជាតូបនីយកម្មដល់ជនបរទេស ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា សាមីខ្លួននោះកើតពីឪពុក ឬម្ដាយ ដែលមានសញ្ជាតិខ្មែរ ឬឯកសារភស្តុតាងផ្លូវការដែលបញ្ជាក់ថា សាមីខ្លួនកើតមកពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ ។

- ត្រូវផ្ដិតមេដៃនៅមុខមេឃុំ ចៅសង្កាត់ ។

## ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Nº XXXXXXX

រាជធានី ខេត្ត ....................
ក្រុង ស្រុក ខណ្ឌ ................
ឃុំ សង្កាត់ ......................
លេខ ..............................

ឯកសារបញ្ជាក់អត្តសញ្ញាណ
បម្រើឱ្យការចុះឈ្មោះបោះឆ្នោត

រូបថត ៣x៤

យោងលិខិតស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី...........ខែ..........ឆ្នាំ............
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ..........................................
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ..............................ភេទ...........សញ្ជាតិ..............
កើតនៅថ្ងៃទី..........ខែ.........ឆ្នាំ...........មានលំនៅឋាន ឬទីសំណាក់លេខ.................ផ្លូវ.................
ភូមិ...................... ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។
....................ថ្ងៃទី......... ខែ......... ឆ្នាំ...........
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Nº XXXXXXX

រាជធានី ខេត្ត ....................
ក្រុង ស្រុក ខណ្ឌ ................
ឃុំ សង្កាត់ ......................
លេខ ..............................

ឯកសារបញ្ជាក់អត្តសញ្ញាណ
បម្រើឱ្យការចុះឈ្មោះបោះឆ្នោត

រូបថត ៣x៤

យោងលិខិតស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី...........ខែ..........ឆ្នាំ............
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ..........................................
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ..............................ភេទ...........សញ្ជាតិ..............
កើតនៅថ្ងៃទី..........ខែ.........ឆ្នាំ...........មានលំនៅឋាន ឬទីសំណាក់លេខ.................ផ្លូវ.................
ភូមិ...................... ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។
....................ថ្ងៃទី......... ខែ......... ឆ្នាំ...........
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់

### ៤. ករណីអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះ

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា មាន អ.ខ ប៉ុន្តែលំនៅឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនកំពុងរស់នៅ ប្រធាន ក.ច.ប ត្រូវចេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះ (ទ.១០០៩) ដោយបញ្ជាក់មូលហេតុច្បាស់លាស់ និងណែនាំអ្នកសុំចុះឈ្មោះតាមករណីដូចខាងក្រោម៖

**ក. ករណីអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះ**

- សូមអ្នកទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ដែលមកសុំចុះឈ្មោះបោះឆ្នោត។
- ប្រសិនបើអ្នកបានទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួបក្រុមចុះឈ្មោះវិញ ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត។

អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ



ឬ




ឬ




សៀវភៅស្នាក់នៅច្បាប់ដើម + សៀវភៅគ្រួសារច្បាប់ដើម




ឬ




ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ហើយអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ ដែលសាមីខ្លួនសុំចុះឈ្មោះ និងគ្មានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់

- សូមអ្នកទៅជួបអាជ្ញាធរឃុំ សង្កាត់ ដោយនាំយកទៅជាមួយនូវ អ.ខ និងសាក្សី ០១ (មួយ) រូបដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាមួយ (សាក្សីរូបនោះត្រូវនាំទៅជាមួយនូវឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់) ដើម្បីបំពេញបែបបទផ្តល់លិខិតបញ្ជាក់ទីលំនៅជូន។
- ប្រសិនបើអ្នកបានទទួលលិខិតបញ្ជាក់ទីលំនៅ ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួបក្រុមចុះឈ្មោះវិញ ដើម្បីបំពេញបែបបទចុះឈ្មោះបោះឆ្នោត។

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ




ឬ




ឬ




\+
លិខិតបញ្ជាក់ទីលំនៅ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ..................
ក្រុង ស្រុក ខណ្ឌ ..................
ឃុំ សង្កាត់ ..................

លេខ: 000000000

លិខិតបញ្ជាក់ទីលំនៅ

យោងប្រកាសលេខ..... ប្រ.ក ចុះថ្ងៃទី.... ខែ...... ឆ្នាំ២០១... របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត។

យើងមេឃុំ ចៅសង្កាត់______________សូមបញ្ជាក់ថា៖
- ឈ្មោះ:______________ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃ____ទីខែ____ឆ្នាំ____ ពិតជាមានលំនៅឋានឬទីសំណាក់
- លេខ____ផ្លូវ____ភូមិ____ឃុំ សង្កាត់____
ក្រុង ស្រុក ខណ្ឌ____រាជធានី ខេត្ត____ពិតប្រាកដមែន។

លិខិតបញ្ជាក់ទីលំនៅនេះធ្វើឡើងដោយផ្អែកលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានលេខ______________និងការឆ្លើយបញ្ជាក់របស់សាមីខ្លួន និងសាក្សី៖
- ឈ្មោះ:______________ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃទី____ខែ____ឆ្នាំ____មានលំនៅឋានឬទីសំណាក់
លេខ____ផ្លូវ____ភូមិ____ឃុំ សង្កាត់____
ក្រុង ស្រុក ខណ្ឌ____រាជធានី ខេត្ត____
ពិតជាត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

លិខិតបញ្ជាក់ទីលំនៅនេះ ចេញជូនសាមីខ្លួន សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត។

ធ្វើនៅថ្ងៃទី........ខែ..........ឆ្នាំ..........

ស្នាមមេដៃ | មេឃុំ ចៅសង្កាត់
សាមីខ្លួន | សាក្សី

### ៥. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឆ្នាំ២០១៦

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់ចុះឈ្មោះបោះឆ្នោតម្តងរួចហើយក្នុងឆ្នាំ២០១៦ ប្រធាន ក.ច.ប ត្រូវសួរសំណួរបន្តថា តើអ្នកធ្លាប់ចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ណា?

#### ក. ករណីអ្នកសុំចុះឈ្មោះបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឆ្នាំ២០១៦ តែបានប្តូរទីលំនៅក្នុងឃុំ សង្កាត់

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនៅក្នុងឆ្នាំ២០១៦ ក្នុងឃុំ សង្កាត់នេះ ប្រធាន ក.ច.ប ត្រូវសុំពិនិត្យមើល អ.ខ បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងឯកសារភស្តុតាងដែលបញ្ជាក់ទីលំនៅថ្មីនៅក្នុងឃុំ សង្កាត់ ដូចជា សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ។ ករណីនេះ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់ឱ្យអនុប្រធានៈ
    - បំពេញទម្រង់បង្កាន់ដៃទទួលការប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០២៨) ចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា និងបោះត្រាបន្ថែមនៅលើ ទ.១០២៨ រវាងគល់ទម្រង់ និងបង្កាន់ដៃ បន្ទាប់មកឱ្យអ្នកស្នើសុំផ្តិតមេដៃ និងសរសេរឈ្មោះ
    - ហែកបង្កាន់ដៃ ទ.១០២៨ ប្រគល់ឱ្យការីកុំព្យូទ័រ
    - ដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតចាស់ (ទ.១០២២) កិបភ្ជាប់ជាមួយគល់ ទ.១០២៨ ដែលត្រូវបញ្ជូនមក គ.ជ.ប
    - ណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ឱ្យការីកុំព្យូទ័រៈ
    - ផ្ទេរឈ្មោះ និងទិន្នន័យអ្នកស្នើសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ទៅការិយាល័យបោះឆ្នោតថ្មី ក្នុងភូមិដែលគាត់រស់នៅ ដូចបានកំណត់ក្នុង ទ.១០២៨
    - ជម្រាបអ្នកស្នើសុំឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន ដែលបានបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ
    - ប្រគល់បង្កាន់ដៃ ទ.១០២៨ ឱ្យអ្នកស្នើសុំ។

**ខ. ករណីអ្នកសុំចុះឈ្មោះ បានចុះឈ្មោះបោះឆ្នោតរួចហើយនៅឆ្នាំ២០១៦ ក្នុងឃុំ សង្កាត់ផ្សេង**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនៅក្នុងឆ្នាំ២០១៦ ក្នុងឃុំ សង្កាត់ផ្សេង ប្រធាន ក.ច.ប ត្រូវៈ

- បន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងជំហានទាំង ៤ នៃការចុះឈ្មោះបោះឆ្នោត
- ឱ្យអនុប្រធាន ក.ច.ប គូសធិកសម្គាល់ក្នុង ទ.១០២២ ដើម្បីបញ្ជាក់ពីករណីនេះ។

**៦. បែបបទ និងនីតិវិធីនៃការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ)**

អនុលោមតាមមាត្រា ៥១ នៃច.ប.គ.រ អាជ្ញាធរឃុំ សង្កាត់ មានសិទ្ធិក្នុងការចេញឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរ ដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួនបានខូច ឬបាត់តាមការស្នើសុំ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។

បែបបទ និងនីតិវិធីនៃការស្នើសុំ និងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ ត្រូវបានកំណត់ដោយសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប។

មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ ឬជនណាដែលក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណ ឬក៏ចេញឯកសារបញ្ជាក់អត្តសញ្ញាណមិនបានត្រឹមត្រូវតាមនីតិវិធី ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ មានសមត្ថកិច្ចចេញឯកសារបញ្ជាក់អត្តសញ្ញាណជូនប្រជាពលរដ្ឋខ្មែរក្នុងឃុំ សង្កាត់របស់ខ្លួនតាមការស្នើសុំរបស់សាមីខ្លួន ដើម្បីយកទៅប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត។

**ចំណាំ៖**

- ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ត្រូវប្រើប្រាស់សម្រាប់តែការចុះឈ្មោះបោះឆ្នោត។

**៧. បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់**

អ្នកសុំចុះឈ្មោះដែលបានបង្ហាញ អ.ខ ប៉ុន្តែលំនៅឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនកំពុងរស់នៅ ហើយសាមីខ្លួនពុំមានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារដែលមានបញ្ជាក់ការស្នាក់នៅរបស់ខ្លួនក្នុងឃុំ សង្កាត់ ដែលគាត់សុំចុះឈ្មោះបោះឆ្នោតនោះ មានសិទ្ធិស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់សម្រាប់ប្រើប្រាស់ក្នុងគោលដៅនៃការសុំចុះឈ្មោះបោះឆ្នោតពីអាជ្ញាធរឃុំ សង្កាត់ដោយត្រូវអនុវត្តតាមនីតិវិធី និងបែបបទណែនាំរបស់ក្រសួងមហាផ្ទៃ។

ផ្អែកតាមសំណើរបស់អ្នកសុំចុះឈ្មោះ អាជ្ញាធរឃុំ សង្កាត់ត្រូវផ្តល់លិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ជូនសាមីជនដែលមានលំនៅឋាន ឬទីសំណាក់ពិតប្រាកដនៅក្នុងឃុំ សង្កាត់នោះ ដោយផ្អែកតាមនីតិវិធី និងបែបបទកំណត់របស់ក្រសួងមហាផ្ទៃ។

អាជ្ញាធរឃុំ សង្កាត់ ដែលបដិសេធការស្នើសុំលិខិតបញ្ជាក់ទីលំនៅរបស់ជនដែលមានលំនៅឋាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់នោះ ដូចបានកំណត់នៅក្នុងច្បាប់បោះឆ្នោត នឹងត្រូវផ្តន្ទាទោសទៅតាមច្បាប់។

បន្ទាប់ពីទទួលបានលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត អ្នកសុំចុះឈ្មោះត្រូវត្រឡប់ទៅជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត ដោយបង្ហាញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដែលទើបនឹងបានទទួលពីអាជ្ញាធរឃុំ សង្កាត់។ ក.ច.ប ត្រូវពិនិត្យលិខិតបញ្ជាក់ទីលំនៅនេះ រួចត្រូវប្រគល់ជូនអ្នកសុំចុះឈ្មោះវិញ។

## V. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីបញ្ហាទាំងឡាយពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានភាពមិនត្រឹមត្រូវដូចមានចែងក្នុងច្បាប់បោះឆ្នោត ឬ/និង ប.ន.ប.ថ ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប។

ពាក្យប្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន ០៣ (បី) ច្បាប់។ ទ.១២០២ នេះ ត្រូវបានប្រគល់ជូនអ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើគាត់ស្នើសុំ។

អ្នកប្តឹងអាចថតចម្លង ទ.១២០២ ដែលខ្លួនបានបំពេញរួចចុះហត្ថលេខា ឬផ្តិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយដាក់ប្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ប្តឹងជួសខ្លួនបាន។ ពាក្យប្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចខាងក្រោម៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- កម្មវត្ថុនៃបណ្តឹង
- ប្រភេទនៃអំពើល្មើស
- ពេលវេលា និងទីកន្លែងនៃការសុំចុះឈ្មោះបោះឆ្នោត ឬបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ឬការប្រព្រឹត្តអំពើល្មើស
- បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោតដែលបានរំលោភ
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន
- ភស្តុតាងផ្សេងៗទៀត បើមាន។

**ចំណាំ៖**

- ☛ ពាក្យប្តឹងអនាមិកពុំត្រូវបានចាត់ទុកជាបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។
- ☛ ការរាប់ចំនួនថ្ងៃប្តឹងតវ៉ា ឬប្តឹងជំទាស់ និងការដោះស្រាយលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការទេ។
- ☛ ករណីអ្នកប្តឹងមកប្តឹងតវ៉ាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរតាមលិខិតផ្សេងៗក្រៅពី ទ.១២០២ កបឃ.ស ត្រូវណែនាំអ្នកប្តឹងឱ្យបំពេញ ទ.១២០២ ចំនួន ០៣ (បី) ច្បាប់។

**១. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងនៅ កបឃ.ស**

អ្នកសុំចុះឈ្មោះបោះឆ្នោតដែលត្រូវបាន ក.ច.ប បដិសេធការសុំចុះឈ្មោះបោះឆ្នោត ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅ កបឃ.ស ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)។

❖ **ការដាក់ និងការទទួលពាក្យបណ្តឹងនៅ កបឃ.ស**

អ្នកប្តឹងត្រូវបំពេញ ទ.១២០២ ទាំង ០៣ (បី) ច្បាប់។ ពាក្យប្តឹងត្រូវដាក់នៅ កបឃ.ស តាមការកំណត់។

- នៅពេលបានទទួលពាក្យប្តឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនដូចជា៖
  - ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬ/និងតំណាង

○ កម្មវត្ថុនៃបណ្តឹង និងការគោរពអំឡុងពេលកំណត់ ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួល ទ.១០០៩។

- បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវធ្វើកំណត់ហេតុសាកសួរព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ។
- បន្ទាប់ពីបានពិនិត្យលើបណ្តឹង និងសួរកត់ត្រាក្នុងកំណត់ហេតុ ហើយឃើញថាៈ
  ○ កម្មវត្ថុនៃបណ្តឹងមិនទាក់ទងនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើបណ្តឹងគ្រប់ច្បាប់ថា «ពាក្យបណ្តឹងនេះពុំស្ថិតក្នុងដែនសមត្ថកិច្ចរបស់ កបឃ.ស ទេ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ»។
  ○ ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់ ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១០០៩ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ថា «ពាក្យបណ្តឹងនេះ ត្រូវបានដាក់ក្រោយអំឡុងពេលកំណត់ដែលជាហេតុផ្តស់សិទ្ធិក្នុងការប្តឹងមក កបឃ.ស។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្តឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ»។
- បន្ទាប់មកចុះហត្ថលេខា បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ ទ.១២០២ ទាំង ០៣ (បី)ច្បាប់ ហើយ ទ.១២០២ ប្រើប្រាស់ដូចខាងក្រោមៈ

ទ.១២០២ ចំនួន ០៣ ច្បាប់
- ០១ ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ០១ ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឱប
- ០១ ច្បាប់ ទុកឯកសារ

- ពាក្យបណ្តឹងមិនមានបញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវជាអាទិ៍ កបឃ.ស ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យប្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹងមិនបានបំពេញ

បន្ថែមនូវចំណុចខ្វះខាត កបឃ.ស ត្រូវចារបដិសេធលើបណ្ដឹងគ្រប់ច្បាប់ ផ្ញើជូនអ្នកប្ដឹងដោយបញ្ជាក់ថា «ពាក្យបណ្ដឹងមិនមានបញ្ជាក់អត្តសញ្ញាណអ្នកប្ដឹង ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ»។

- បើអ្នកប្ដឹងយកបណ្ដឹង (ទ.១២០២) មកដាក់ក្នុងអំឡុងពេលកំណត់ ហើយកម្មវត្ថុនៃបណ្ដឹងទាក់ទងនឹងការសុំចុះឈ្មោះបោះឆ្នោត និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រាឃុំ សង្កាត់លើពាក្យបណ្ដឹងគ្រប់ច្បាប់ ហើយបំពេញកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលនឹងត្រូវបើកការប្រជុំសម្រេច រួចប្រគល់ជូនអ្នកប្ដឹងចំនួន ០១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈចំនួន ០១ (មួយ) ច្បាប់ និងរក្សាទុកប្រើក្នុងការប្រជុំសម្រេច ០១ (មួយ) ច្បាប់។

ទ.១២០២ ចំនួន ០៣ ច្បាប់
- ០១ ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ០១ ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់
- ០១ ច្បាប់ ទុកប្រើប្រាស់ក្នុងការប្រជុំសម្រេច។

❖ **ការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស**

កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលបណ្ដឹង ដោយផ្អែកលើ៖

- មូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ តាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះបោះឆ្នោត
- សំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ទាំងមូល និងករណីមានសំឡេងស្មើគ្នា សំឡេងរបស់អធិបតីនៃកិច្ចប្រជុំ មានឧត្តមានុភាព
- មូលហេតុនៃការបដិសេធលើ ទ.១០០៩ របស់ ក.ច.ប។

**ករណីសម្រេចយល់ព្រមលើពាក្យបណ្ដឹង**

- ធ្វើកំណត់ហេតុប្រជុំសម្រេច
- លេខាធិការអង្គប្រជុំសម្រេច ត្រូវស្រង់សេចក្ដីសម្រេចយល់ព្រមចេញពីកំណត់ហេតុប្រជុំសម្រេចដាក់ចូលក្នុង ទ.១២០៣ ចំនួន ០៣ (បី) ច្បាប់ រួចចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ ហើយ ទ.១២០៣ ប្រើប្រាស់ដូចខាងក្រោម៖

ទ.១២០៣ ចំនួន ០៣ ច្បាប់
- ០១ ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ០១ ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប
- ០១ ច្បាប់ រក្សាទុកជាឯកសារ

- ចាត់ ក.ច.ប ឱ្យអនុវត្តការចុះឈ្មោះដូចចែងក្នុងជំហានទាំង ៤ នៃការចុះឈ្មោះបោះឆ្នោត។

**ករណីសម្រេចបដិសេធលើបណ្ដឹង**

- ធ្វើកំណត់ហេតុប្រជុំសម្រេច
- លេខាធិការអង្គប្រជុំសម្រេច ត្រូវស្រង់សេចក្ដីសម្រេចបដិសេធចេញពីកំណត់ហេតុប្រជុំសម្រេចចូលក្នុង ទ.១២០៣ ទាំង ០៣ (បី) ច្បាប់ រួចចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំ និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេចហើយបោះត្រាឃុំសង្កាត់ និងចុះកាលបរិច្ឆេទ ហើយ ទ.១២០៣ ប្រើប្រាស់ដូចខាងក្រោម៖

ទ.១២០៣ ចំនួន ០៣ ច្បាប់ {
- ០១ ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ០១ ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប
- ០១ ច្បាប់ ទុកជាឯកសារ។

- ជម្រាបអ្នកប្ដឹងថា គាត់អាចប្ដឹងតវ៉ាទៅនឹងសេចក្ដីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣
- ជូនអ្នកប្ដឹង ទ.១២០២ ចំនួន ០៣ (បី) ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)។

**២. ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងនៅ គ.ជ.ប**

អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្ដឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។ អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ០៣ (បី) ច្បាប់។

គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈសម្រេចលើបណ្ដឹងក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួលពាក្យបណ្ដឹង។

**៣. ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**

អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយបណ្ដឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចលើពាក្យបណ្ដឹងតវ៉ាដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលបណ្ដឹង។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ៨. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយបណ្តឹងក្នុងដំណាក់កាលនៃការចុះឈ្មោះ



## VI. របាយការណ៍សរុបស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប

### ១. របាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១)

នៅពេលដែលការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ក.ច.ប ត្រូវបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១)។

- ប្រសិនបើគ្មានបណ្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះ ត្រូវបានដាក់ពាក្យប្តឹងទៅ កបឃ.ស ក្នុងរយៈពេល ០៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ឱ្យរួចរាល់នៅមុនពេលត្រូវវេចខ្ចប់បញ្ជូនកញ្ចប់ «ក» ដែលនឹងត្រូវអនុវត្តនៅថ្ងៃទី ០៤ (បួន) បន្ទាប់ពីថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត។
- ប្រសិនបើមានបណ្តឹងតវ៉ានឹងការបដិសេធការចុះឈ្មោះបោះឆ្នោតមួយ ឬច្រើនត្រូវបានដាក់ពាក្យប្តឹងទៅ កបឃ.ស ក.ច.ប ត្រូវ ទ.១០១១ ពាក់ព័ន្ធក្នុងឃុំ សង្កាត់ បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយបណ្តឹងចប់ និងនៅមុនពេលវេចខ្ចប់បញ្ជូនកញ្ចប់ «ក» ដែលអាចនឹងត្រូវអនុវត្តនៅថ្ងៃទី ០៧ (ប្រាំពីរ) បន្ទាប់ពីថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោត។
- ក.ច.ប ត្រូវបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ០៤ (បួន) ច្បាប់ សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗដោយឡែកពីគ្នាហើយ ទ.១០១១ ប្រើប្រាស់ដូចខាងក្រោមៈ

ទ.១០១១ ចំនួន ០៤ ច្បាប់
- ០១ ច្បាប់ ច្រកស្រោមសំបុត្រ សម្រាប់ដាក់ក្នុងកញ្ចប់ «ក»
- ០២ ច្បាប់ កិបភ្ជាប់នៅផ្នែកខាងក្រៅកញ្ចប់ «ក»
- ០១ ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ

### ២. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យនីមួយៗ

ក្រោយពីបានបំពេញរបាយការណ៍ ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោតណាមួយរួចភ្លាម ក.ច.ប ត្រូវរៀបចំវេចខ្ចប់រាល់ឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះដាក់ចូលក្នុងកញ្ចប់ «ក» និងត្រូវសរសេរលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ និងលេខកូដការិយាល័យបោះឆ្នោត សម្គាល់ពីខាងក្រៅកញ្ចប់ «ក» នោះផង។

**ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់ «ក» មានៈ**

- ស្រោមសំបុត្រដាក់រាល់សេចក្តីសម្រេចរបស់ កបឃ.ស យល់ព្រមលើបណ្តឹងតវ៉ា (ទ.១២០៣) ដែលតម្រូវឱ្យ ក.ច.ប ចុះឈ្មោះអ្នកប្តឹងតវ៉ាសុំចុះឈ្មោះទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ។

- ស្រោមសំបុត្រដាក់របាយការណ៍ ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ០១ (មួយ) ច្បាប់។
- ស្រោមសំបុត្រដាក់គល់ទម្រង់បង្កាន់ដៃទទួលការប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០២៨)។




ប្រធាន ក.ច.ប ត្រូវធានាថា៖

- បានដាក់ឯកសារត្រឹមត្រូវហើយមុននឹងចងមាត់កញ្ចប់ «ក» ។
- បានវេចខ្ចប់ និងចងមាត់កញ្ចប់ «ក» ចំពោះមុខសមាជិក កបឃ.ស ប្រចាំការ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។
- បានសរសេរលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ការិយាល័យ នៅលើកញ្ចប់ «ក» ត្រឹមត្រូវ ដោយប៊ិកហ្វឺតលុបមិនជ្រះ។
- ទ.១០១១ ចំនួន ០២ (ពីរ) ច្បាប់ ត្រូវបានកិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ «ក»
- ថែរក្សាឱ្យបានល្អមុនវេចខ្ចប់ចូលស្បោង «ខ»។

**៣. របាយការណ៍សរុបស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២)**

ប្រសិនបើគ្មានបណ្តឹងតវ៉ាត្រូវបានដាក់ពាក្យប្តឹងទៅ កបឃ.ស ក្នុងរយៈពេល ០៣ (បី) ថ្ងៃបន្ទាប់ពីថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍សរុបស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ឱ្យរួចរាល់ នៅមុនពេលត្រូវវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ»។

ប្រសិនបើមានបណ្ដឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតមួយ ឬច្រើនត្រូវបានដាក់ពាក្យប្ដឹងទៅ កបឃ.ស គ.ច.ប ត្រូវធ្វើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយបណ្ដឹងចប់ និងនៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ»។

គ.ច.ប ត្រូវបំពេញរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ចំនួន ០៣ (បី) ច្បាប់។ របាយការណ៍នេះត្រូវមានបញ្ជាក់តួលេខលទ្ធផលដែលបានមកពីការបូកសរុបបញ្ចូលគ្នានូវតួលេខក្នុងរបាយការណ៍ ស្ដីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។

**ការប្រើប្រាស់ ទ.១០១២**

ទ.១០១២ ចំនួន ០៣ ច្បាប់
- ០២ ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «ខ» (ផ្ញើជូន គ.ជ.ប ០១ ច្បាប់ និងផ្ញើជូន លធ.ខប ០១ ច្បាប់)
- ០១ ច្បាប់ គ.ច.ប រក្សាទុកជាឯកសារ បន្ទាប់មករក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់

នៅក្រោយពេលបានបំពេញរបាយការណ៍សរុប ស្ដីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់រួចភ្លាម គ.ច.ប ត្រូវរៀបចំវេចខ្ចប់កញ្ចប់ «ក» និងរាល់សម្ភារ ឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ដាក់ទៅក្នុងស្បោង «ខ» តាមចំនួនដែលអាចដាក់បាន។

**៤. របាយការណ៍ស្ដីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១)**

គ.ច.ប ត្រូវបន្តបំពេញរបាយការណ៍ស្ដីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ០៤ (បួន) ច្បាប់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឱ្យប្រាកដថា ទ.១០២២ ដែលបានទទួលស្មើនឹង ទ.១០២២ ដែលបានប្រើប្រាស់បូកនឹង ទ.១០២២ ដែលនៅសល់មិនទាន់ប្រើ។ ទ.១០២១ ប្រើប្រាស់ដូចខាងក្រោម៖

ទ.១០២១ ចំនួន ០៤ ច្បាប់
- ០១ ច្បាប់ច្រកក្នុងស្រោមសំបុត្ររួចដាក់ក្នុងកញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយ
- ០១ ច្បាប់កិបភ្ជាប់ផ្នែកខាងក្រៅនៃកញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយ
- ០១ ច្បាប់ ច្រកក្នុងស្រោមសំបុត្ររួចដាក់ក្នុងកញ្ចប់ដាក់សៀវភៅ ទ.១០២២ ដែលនៅសល់មិនទាន់ប្រើ
- ០១ ច្បាប់ គ.ច.ប រក្សាទុកជាឯកសារ។

**៥. កញ្ចប់ដាក់គល់សៀវភៅសន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និង កញ្ចប់ដាក់សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់**

គ.ច.ប ត្រូវធានាថា រាល់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងសៀវភៅ ទ.១០២២ ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ត្រូវដាក់ទៅក្នុងកញ្ចប់មួយដោយឡែកពីគ្នា ដែលត្រៀមបម្រុងស្រាប់ ដោយដាក់ភ្ជាប់ជាមួយនូវរបាយការណ៍ស្ដីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បែបបទនេះផង។

ក. កញ្ចប់ដាក់គល់សៀវភៅសន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់នេះមាន៖

- រាល់គល់សៀវភៅសន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ (ទ.១០២២) ដែលបានប្រើហើយ (គិតទាំងខូច និងនៅសល់ក្នុងដុំដែលបានប្រើហើយ) សរុបក្នុងឃុំ សង្កាត់
- ស្រោមសំបុត្រដាក់ ទ.១០២១ ចំនួន ០១ (មួយ) ច្បាប់

**កញ្ចប់ដាក់គល់សៀវភៅសន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលបានប្រើហើយ សរុបក្នុងឃុំ សង្កាត់**

**រាជធានី ខេត្ត** **ឃុំ សង្កាត់**

- រាល់គល់សៀវភៅសន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលបានប្រើហើយ (គិតទាំងខូច និងនៅសល់ក្នុងដុំដែលបាន ប្រើហើយ) សរុបក្នុងឃុំ សង្កាត់។
- ស្រោមសំបុត្រដាក់ ទ.១០២១ ចំនួន ០១ (មួយ) ច្បាប់។

ទ.១០២១ ចំនួន ០១ ច្បាប់

បន្ទាប់ពីវេចខ្ចប់កញ្ចប់នោះរួច ក.ច.ប ត្រូវ៖

- កិបភ្ជាប់ ទ.១០២១ ចំនួន ០១ (មួយ) ច្បាប់នៅផ្នែកខាងក្រៅកញ្ចប់
- សរសេរលេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់នៅលើកញ្ចប់ឱ្យបានត្រឹមត្រូវច្បាស់លាស់។

ខ. កញ្ចប់ដាក់សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់នេះមាន៖

- សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់។
- ស្រោមសំបុត្រដាក់ ទ.១០២១ ចំនួន ០១ (មួយ) ច្បាប់។

| |
|---|
| **កញ្ចប់ដាក់សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់**<br>☐☐ ☐☐☐<br>**រាជធានី ខេត្ត** **ឃុំ សង្កាត់**<br>- សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលនៅសល់មិនទាន់ប្រើ សរុបក្នុងឃុំ សង្កាត់។<br>- ស្រោមសំបុត្រដាក់ ទ.១០២១ ចំនួន ០១ (មួយ) ច្បាប់។ |

បន្ទាប់ពីវេចខ្ចប់កញ្ចប់នោះរួច ក.ច.ប ត្រូវ សរសេរលេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់នៅលើកញ្ចប់ឱ្យបានត្រឹមត្រូវច្បាស់លាស់។

**បញ្ជាក់៖**

- កញ្ចប់ដាក់សៀវភៅទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ត្រូវប្រគល់ឱ្យ ន. ប្រតិបត្តិការ។

**៦. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប**

សម្ភារ ឯកសារដែលបានរៀបចំវេចខ្ចប់រួច ក.ច.ប ត្រូវរៀបចំដាក់ក្នុងស្បោង «ខ» បន្តទៀតដើម្បីបញ្ជូនទៅ លធ.ខប។

ក.ច.ប ត្រូវបំពេញលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង «ខ» (ទ.១០១៣) ចំនួន ០៤ (បួន) ច្បាប់។ ទ.១០១៣ ប្រើប្រាស់ដូចខាងក្រោម៖

ទ.១០១៣ ចំនួន ០៤ ច្បាប់
- ០២ ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «ខ»
- ០១ ច្បាប់ ដាក់ហោប៉ៅខាងក្រៅនៃស្បោង «ខ»
- ០១ ច្បាប់ ទុកសម្រាប់ពេលប្រគល់ទទួលនៅ លធ.ខប (ក្រោយមកទុកជាឯកសារឃុំ សង្កាត់)

**ក. ការវេចខ្ចប់ស្បោង «ខ» ទី ១**

សម្ភារ ឯកសារដែលត្រូវដាក់ក្នុងស្បោង «ខ» ទី ១ មាន៖

- កញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយ (គិតទាំងខូច និងនៅសល់ក្នុងដុំដែលបានប្រើហើយ) សរុបក្នុងឃុំ សង្កាត់
- កញ្ចប់ដាក់សៀវភៅ ទ.១០២២ ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់

- ស្រោមសំបុត្រដាក់របាយការណ៍សរុប ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ចំនួន ០២ (ពីរ) ច្បាប់
- ស្រោមសំបុត្រដាក់រាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារឯកសារចុះឈ្មោះបោះឆ្នោត និង ការបញ្ជូនស្បោង «ខ» (ទ.១០១៣) ចំនួន ០២ (ពីរ) ច្បាប់។




**ចំណាំ៖** ករណីស្បោង «ខ» ទី ១ មានចំនួនសរុបលើសពីមួយ ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង «ខ» ទី ១ ទាំងនោះនូវលេខនៃស្បោងនីមួយៗ។ ឧទាហរណ៍ ស្បោង «ខ» ទី ១ សរុបមានចំនួន ២ ត្រូវសរសេរសម្គាល់នូវលេខរៀងថា ១/២ ២/២។

### ខ. ការវេចខ្ចប់ស្បោង «ខ» ទី ២ និងស្បោង «ខ» បន្តបន្ទាប់

សម្ភារ ឯកសារដែលត្រូវដាក់ក្នុងស្បោង «ខ» ទី ២ និងស្បោង «ខ» បន្តបន្ទាប់រួមមាន៖

- កញ្ចប់ «ក» តាមចំនួនដែលអាចដាក់បានក្នុងស្បោង «ខ» នីមួយៗ។ កញ្ចប់ «ក» ដែលត្រូវដាក់ក្នុងស្បោង «ខ» តែមួយ ត្រូវតែបានរៀបចំតាមលេខរៀងជាប់គ្នា និងតាមលំដាប់លំដោយ
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង «ខ» (ទ.១០១៣) ចំនួន ០២ (ពីរ) ច្បាប់។



**ចំណាំ៖** ករណីស្បោង «ខ» ទី ២ មានចំនួនសរុបលើសពីមួយ ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង «ខ» ទី ២ ទាំងនោះនូវលេខនៃស្បោងនីមួយៗ។ ឧទាហរណ៍ ស្បោង «ខ» ទី ២ សរុបមានចំនួន ៣ ត្រូវសរសេរសម្គាល់នូវលេខរៀងថា ១/៣ ២/៣ ៣/៣។

**បញ្ជាក់៖**

មុននឹងចងមាត់ស្បោង «ខ» ក.ច.ប ត្រូវធានាថា មិនត្រូវឱ្យមាននៅសល់សម្ភារ ឯកសារណាមួយដែលភ្លេចមិនទាន់ដាក់ក្នុងស្បោង «ខ» នីមួយៗនោះឡើយ។ ស្បោង «ខ» ដែលចងមាត់រួចអាចបើកឡើងវិញបានតែក្នុងពេលបំពេញភារកិច្ចត្រួតពិនិត្យ ការទទួលសម្ភារ ឯកសារនៅ លធ.ខប និងនៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតប៉ុណ្ណោះ។

ពេលចងមាត់ស្បោង «ខ» រួច ក.ច.ប ត្រូវធានាថា៖

- ដាក់ ទ.១០១៣ ចំនួន ០១ (មួយ) ច្បាប់ ក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ»
- សរសេរសម្គាល់លេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ឱ្យបានត្រឹមត្រូវ ដោយប៊ិកហ្វឺតលុបមិនជ្រះនៅត្រង់ចន្លោះទំនេរផ្នែកខាងលើហោប៉ៅខាងក្រៅនៃស្បោង «ខ»
- ថែរក្សាសុវត្ថិភាពឱ្យបានល្អនៅមុនពេល និងក្នុងពេលបញ្ជូនទៅ លធ.ខប។

ការវេចខ្ចប់ និងការចងមាត់ស្បោង «ខ» ត្រូវធ្វើនៅចំពោះមុខសមាជិក កបឃ.ស ប្រចាំការ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

**៧. ការបញ្ជូនស្បោង «ខ» ទៅ លធ.ខប**

- ក.ច.ប ត្រូវទទួលបន្ទុកការបញ្ជូន និងការប្រគល់ស្បោង «ខ» ដោយផ្ទាល់នៅ លធ.ខប
- លធ.ខប អាចចាត់មន្ត្រីរបស់ខ្លួនឱ្យចុះត្រួតពិនិត្យ និងទទួលយកស្បោង «ខ» នៅតាមឃុំ សង្កាត់ក៏បាន
- មន្ត្រី លធ.ខប ដែលទទួលបន្ទុកទទួលឯកសារត្រូវចុះហត្ថលេខាលើ ទ.១០១៣ ទាំង ០៤ (បួន) ច្បាប់ រួចប្រគល់ឱ្យ ក.ច.ប ០១ (មួយ) ច្បាប់វិញទុកជាឯកសារនៅសាលាឃុំ សង្កាត់
- ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ប្រចាំឃុំ សង្កាត់នីមួយៗអាចរួមដំណើរសង្កេតមើល និងអាចធ្វើជាសាក្សីក្នុងការប្រគល់ ទទួលស្បោង «ខ»។

**៨. ការត្រួតពិនិត្យ និងការវេចខ្ចប់ស្បោង «ខ» នៅ លធ.ខប និងការវេចខ្ចប់ស្បោង «ខ» ដាក់ក្នុងស្បោង «គ» បញ្ជូនមក ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត**

នៅពេលប្រគល់ទទួលស្បោង «ខ» ពី ក.ច.ប មន្ត្រី លធ.ខប ត្រូវត្រួតពិនិត្យថា ស្បោង «ខ» ទាំងឡាយមិនត្រូវបានគេរុះរើឡើយ។ នៅចំពោះមុខ ក.ច.ប នៃឃុំ សង្កាត់ពាក់ព័ន្ធ មន្ត្រី លធ.ខប ត្រូវត្រួតពិនិត្យឱ្យប្រាកដថា ស្បោង «ខ» នីមួយៗមានផ្ទុកកញ្ចប់

«ក» និងកញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតគ្រប់ចំនួន។

**ក. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប**

➢ **ករណីស្បោង «ខ» មិនមានការរុះរើ**

ក្នុងការត្រួតពិនិត្យ ប្រសិនបើមន្ត្រី លធ.ខប មិនឃើញមានស្បោង «ខ» ណាមួយត្រូវបានគេរុះរើទេ ត្រូវបន្តការត្រួតពិនិត្យ ដោយការបើកស្បោង «ខ»ម្តងមួយៗ ដើម្បីផ្ទៀងផ្ទាត់ចំនួនកញ្ចប់ «ក» កញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់ផ្សេងទៀតដែលមានក្នុងស្បោង «ខ» នោះ។

មន្ត្រី លធ.ខប ត្រូវបើកស្បោង «ខ» ម្តងមួយៗរហូតដល់អស់ស្បោង «ខ» នៃឃុំ សង្កាត់ពាក់ព័ន្ធដើម្បីផ្ទៀងផ្ទាត់កញ្ចប់ «ក» កញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតដែលមាននៅខាងក្នុងយ៉ាងហ្មត់ចត់ ដោយផ្អែកលើ ទ.១០១៣ ដែលដាក់ក្នុងហោប៉ៅក្រៅនៃស្បោង «ខ»។ ប្រសិនបើគ្មានកញ្ចប់ «ក» ឬកញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ណាមួយត្រូវបានរុះរើទេ មន្ត្រី លធ.ខប ត្រូវ៖

- គ្រាន់តែពិនិត្យ និងរាប់ចំនួនកញ្ចប់ «ក» និងកញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ឬស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតប៉ុណ្ណោះ ដោយមិនចាំបាច់បើកកញ្ចប់ «ក» ឬកញ្ចប់សម្ភារ ឯកសារទាំងនោះដើម្បីធ្វើការផ្ទៀងផ្ទាត់ឡើងវិញទេ
- ដកយក ទ.១០១១ ចំនួន ០១ (មួយ) ច្បាប់ ក្នុងចំណោម ០២ (ពីរ) ច្បាប់ ដែលកិបភ្ជាប់នៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ «ក» ដើម្បីប្រើសម្រាប់ផ្ទៀងផ្ទាត់ និងរក្សាទុកជាឯកសារ
- ដកយក ទ.១០១៣ ដែលមានក្នុងស្រោមសំបុត្រក្នុងស្បោង «ខ» ចំនួន ០២ (ពីរ) ច្បាប់ក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ» ចំនួន ០១ (មួយ) ច្បាប់ និងយក ០១ (មួយ) ច្បាប់ទៀតពី ក.ច.ប រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា ហើយប្រគល់ ០១ (មួយ) ច្បាប់ជូន ក.ច.បវិញ ដើម្បីបញ្ជាក់ថាបានទទួល
- រៀបចំដាក់កញ្ចប់ «ក» កញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតទៅក្នុងស្បោង «ខ» ដដែលវិញ រួចច្រក ទ.១០១៣ ចំនួន ០១ (មួយ) ច្បាប់ក្នុងស្រោមសំបុត្រដាក់ទៅក្នុងស្បោង «ខ» និងដាក់ ០១ (មួយ) ច្បាប់ទៀតទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ»

- ចងភ្ជិតមាត់ស្បោង «ខ» រួចរក្សាទុកម្ដុំនៅកន្លែងមានសុវត្ថិភាពសម្រាប់ត្រៀមវេចខ្ចប់ក្នុងស្បោង «គ» ដើម្បីបញ្ជូនមក គ.ជ.ប។

➢ **ករណីស្បោង «ខ» មានការរុះរើ**

ក្នុងការត្រួតពិនិត្យ ប្រសិនបើមន្ត្រី លធ.ខប រកឃើញថា មានស្បោង «ខ» ណាមួយត្រូវបានគេរុះរើ ក.ច.ប ដែលបានបញ្ជូន និងប្រគល់ស្បោង «ខ» ពាក់ព័ន្ធនឹងត្រូវបានស្នើឱ្យបកស្រាយបំភ្លឺករណីនេះ។

ប្រសិនបើក្នុងការត្រួតពិនិត្យខាងលើមានភស្តុតាងបញ្ជាក់ថា មានកញ្ចប់ «ក» ណាមួយ ឬកញ្ចប់ដាក់គល់សៀវភៅសន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ នៅក្នុងស្បោង «ខ» ត្រូវបានគេរុះរើ មន្ត្រី លធ.ខប ត្រូវៈ

- បើកកញ្ចប់ «ក» ដែលមានការរុះរើនោះ និងផ្ទៀងផ្ទាត់សម្ភារ ឯកសារមាននៅខាងក្នុងយ៉ាងហ្មត់ចត់ទៅនឹង ទ.១០១១ ដែលមាននៅខាងក្នុងកញ្ចប់ «ក» និងមានកិបភ្ជាប់នៅផ្នែកខាងក្រៅនៃកញ្ចប់ «ក»
- ដកយក ទ.១០១១ ចំនួន ០១ (មួយ) ច្បាប់ក្នុងចំណោម ០២ (ពីរ) ច្បាប់ដែលមានកិបភ្ជាប់នៅផ្នែកខាងក្រៅនៃកញ្ចប់ «ក» ដើម្បីប្រើ និងរក្សាទុកជាឯកសារ។
- ឱ្យ ក.ច.ប ដែលបានបញ្ជូន និងប្រគល់ស្បោង «ខ» ធ្វើការស្រាយបំភ្លឺក្នុងករណីដែលបានរកឃើញថា មានភាពមិនត្រឹមត្រូវ
- តែងតាំងក្រុមស្រាវជ្រាវមួយដែលមានសមាសភាព ០២ (ពីរ) នាក់ ជាបន្ទាន់ដើម្បីសហការជាមួយ ក.ច.ប ពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវរាល់សម្ភារ ឯកសារដែលមានក្នុងកញ្ចប់ «ក» ទៅនឹង ទ.១០១១ ទ.១០១២ និងឯកសារពាក់ព័ន្ធផ្សេងទៀត
- ធ្វើរបាយការណ៍លម្អិតអំពីភស្តុតាងនៃអំពើល្មើស និងលទ្ធផលនៃការរកឃើញជូន គ.ជ.ប ជាបន្ទាន់ក្នុងករណីដែលក្រុមស្រាវជ្រាវនៃ លធ.ខប បានរកឃើញថា មានការក្លែងបន្លំក្នុងការចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ
- វេចខ្ចប់កញ្ចប់ «ក» ដែលមានបញ្ហាឡើងវិញ រួចបន្តពិនិត្យកញ្ចប់ «ក» ដទៃទៀត
- ត្រូវសរសេរបន្ថែមនូវមូលវិចារអំពីកញ្ចប់ «ក» ដែលត្រូវរុះរើ និងកត់ត្រាលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធលើ ទ.១០១៣ គ្រប់ច្បាប់។

មន្ត្រី លធ.ខប ត្រូវរៀបចំគម្រោងផែនការទទួល ត្រួតពិនិត្យ វេចខ្ចប់ និងបញ្ជូនសម្ភារ ឯកសារនៃការចុះឈ្មោះបោះឆ្នោតទៅ គ.ជ.ប ដែលអាចនឹងត្រូវអនុវត្តនៅចន្លោះរយៈពេល ០៤ (បួន) ថ្ងៃទៅ ១២ (ដប់ពីរ) ថ្ងៃ ក្រោយថ្ងៃបញ្ចប់ការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់។

នៅពេលបានទទួល ត្រួតពិនិត្យ និងវេចខ្ចប់ស្បោង «ខ» ឡើងវិញរួចហើយ មន្ត្រី លធ.ខប ត្រូវចាត់ចែងវេចខ្ចប់ស្បោង «ខ» ដោយដាក់ក្នុងស្បោង «គ» សម្រាប់បញ្ជូន

និងប្រគល់ទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតឱ្យឆាប់បំផុតតាមដែលអាចធ្វើបាន។

**ចំណាំ៖**

- គ.ជ.ប ត្រូវមានវិធានការផ្តន្ទាទោសចំពោះជនល្មើស ដោយផ្អែកលើរបាយការណ៍ និងភស្តុតាង ដែលមន្ត្រី លធ.ឧប បានបញ្ជូនមក។

**ខ. ការវេចខ្ចប់ស្បោង «គ» បញ្ជូនមក ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត**

នៅមួយថ្ងៃមុនថ្ងៃបញ្ជូន និងប្រគល់ស្បោង «គ» ទៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត មន្ត្រី លធ.ឧប ត្រូវ៖

- ច្រកស្បោង «ខ» ទាំងអស់ដែលបានចងមាត់រួចហើយបញ្ចូលទៅក្នុងស្បោង «គ» តាមចំនួនដែលត្រូវការចាំបាច់ដើម្បីដាក់ឱ្យអស់ស្បោង «ខ»
- បំពេញលិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» (ទ.១០១៤) ចំនួន ០៣ (បី) ច្បាប់ដោយចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឱ្យបានត្រឹមត្រូវ និង ទ.១០១៤ ប្រើប្រាស់ ដូចខាងក្រោម៖

ទ.១០១៤ចំនួន០៣ច្បាប់
- ០១ ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «គ»
- ០១ ច្បាប់ ដាក់ហោប៉ៅខាងក្រៅនៃស្បោង «គ»
- ០១ ច្បាប់ទុកឱ្យមន្ត្រី លធ.ឧប ប្រើពេលប្រគល់ ទទួលនៅ គ.ជ.ប

- ដាក់រាល់ស្រោមសំបុត្រដែលមានលិខិតបញ្ជាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតដែលបានផ្គត់ផ្គង់បន្ថែម (ទ.១០១៥) ដែលត្រូវផ្ញើជូន ន. ប្រតិបត្តិការ
- រួតខ្សែចងមាត់ស្បោង «គ» រួចត្រូវបំពេញលេខកូដរាជធានី ខេត្ត នៅក្នុងប្រឡោះដែលបោះពុម្ពស្រាប់ នៅផ្នែកខាងលើហោប៉ៅខាងក្រៅនៃស្បោង «គ» នីមួយៗ។

**សម្ភារ ឯកសារដែលត្រូវដាក់ក្នុងស្បោង «គ» រួមមាន៖**

- ស្បោង «ខ» តាមចំនួនដែលអាចដាក់បាន
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» (ទ.១០១៤) ចំនួន ០១ (មួយ) ច្បាប់
- រាល់ស្រោមសំបុត្រដាក់លិខិតបញ្ជាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតដែលត្រូវបានផ្គត់ផ្គង់បន្ថែម (ទ.១០១៥) ដែលត្រូវផ្ញើជូន ន. ប្រតិបត្តិការ។




ពេលចងមាត់ស្បោង «គ» រួច លធ.ខប ត្រូវ៖

- សរសេរលេខកូដរាជធានី ខេត្ត
- ដាក់ ទ.១០១៤ ចំនួន ០១ (មួយ) ច្បាប់ក្នុងហោប៉ៅខាងក្រៅនៃស្បោង «គ»។

**ការប្រគល់ ទទួលស្បោង «គ» នៅ គ.ជ.ប**

នៅរាល់ពេលនៃការប្រគល់ ទទួលស្បោង «គ» នៅ គ.ជ.ប មន្ត្រីទទួលបន្ទុកការបញ្ជូននៃ លធ.ខប ត្រូវធានាថា មន្ត្រីទទួលសម្ភារ ឯកសារនៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតបានចុះហត្ថលេខាលើ ទ.១០១៤ ទាំង ០៣ (បី) ច្បាប់រួចប្រគល់ឱ្យ មន្ត្រីទទួលបន្ទុកការបញ្ជូននៃ លធ.ខប វិញ ០១ (មួយ) ច្បាប់ ដើម្បីបញ្ជាក់ថាបានទទួលគ្រប់ចំនួន។

**៩. ការវេចខ្ចប់សម្ភារ ឯកសារផ្សេងៗទៀតដែលបានផ្គត់ផ្គង់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតបញ្ជូនមក គ.ជ.ប**

រាល់សម្ភារ បរិក្ខារបម្រើឱ្យការចុះឈ្មោះបោះឆ្នោតដែលនៅសល់ក្រៅពីការវេចខ្ចប់ដាក់ក្នុងស្បោង «គ» មន្ត្រី លធ.ខប ត្រូវធ្វើការពិនិត្យប្រមូលវេចខ្ចប់នូវរាល់សម្ភារ បរិក្ខារ និងឯកសារបម្រើឱ្យការចុះឈ្មោះបោះឆ្នោតផ្សេងទៀតដែលតម្រូវឱ្យប្រគល់មក គ.ជ.ប វិញ ទន្ទឹម

នឹងការបញ្ជូន និងការប្រគល់ស្បោង «គ» នៅ ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។

សម្ភារ បរិក្ខារនៅសល់ ត្រូវប្រគល់ ទទួលនៅឃ្លាំងរបស់ គ.ជ.ប។

## VII. ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងជាសាធារណៈសម្រាប់គោលដៅនៃការប្តឹងតវ៉ា ឬការប្តឹងជំទាស់

បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួចរាល់ គ.ជ.ប ត្រូវបោះពុម្ព និងចាត់ឱ្យផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះអ្នកដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ នៅតាមសាលាឃុំ សង្កាត់ និងទីតាំងណាមួយក្នុងឃុំ សង្កាត់ តាមការកំណត់របស់ គ.ជ.ប ក្នុងគោលដៅនៃការប្តឹងតវ៉ា ឬការប្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង។

គណបក្សនយោបាយ ដែលបានចុះបញ្ជីស្របច្បាប់ស្តីពីគណបក្សនយោបាយមានសិទ្ធិសុំបញ្ជីបោះឆ្នោតដំបូងច្បាប់ថតចម្លងបានដោយបង់ថ្លៃ។តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។

### ១. ទីកន្លែងផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង

- បិទផ្សាយចំនួន ០១ (មួយ) ច្បាប់ រួមនឹងបញ្ជីឈ្មោះអ្នកដែលត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ នៅសាលាឃុំ សង្កាត់
- បិទផ្សាយចំនួន ០១ (មួយ) ច្បាប់ រួមនឹងបញ្ជីឈ្មោះដែលនឹងត្រូវលុបក្នុងឃុំ សង្កាត់ នៅទីតាំងណាមួយក្នុងឃុំ សង្កាត់ និងរក្សាទុក ០១ (មួយ) ច្បាប់ សម្រាប់ប្រើប្រាស់តាមការចាំបាច់ និងតាមកំណត់របស់ គ.ជ.ប
- បង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប (www.voterlist.org.kh)។

កបឃ.ស ត្រូវធ្វើកំណត់ហេតុនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងចំនួន ០៤ (បួន) ច្បាប់ ដោយបញ្ជាក់អំពីពេលវេលា កាលបរិច្ឆេទ ទីកន្លែងបិទផ្សាយ ចុះហត្ថលេខា និងបោះត្រារួចត្រូវ៖

- បិទក្បែរនឹងបញ្ជីបោះឆ្នោតដំបូងដែលត្រូវបិទផ្សាយនៅសាលាឃុំ សង្កាត់ចំនួន ០១ (មួយ) ច្បាប់
- បិទក្បែរនឹងបញ្ជីបោះឆ្នោតដំបូង ដែលត្រូវបិទផ្សាយនៅទីតាំងណាមួយក្នុងឃុំ សង្កាត់ចំនួន ០១ (មួយ) ច្បាប់
- ទុកជាឯកសារនៅសាលាឃុំ សង្កាត់ចំនួន ០១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ចំនួន ០១ (មួយ) ច្បាប់។

### ២. កាលបរិច្ឆេទនៃការផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង

ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ទូទាំងប្រទេសត្រូវធ្វើនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧។

ក្នុងរយៈពេលបិទផ្សាយ កបឃ.ស ស្មៀន និងមេភូមិត្រូវផ្សព្វផ្សាយបំផុសលើកទឹកចិត្តប្រជាពលរដ្ឋអ្នកបោះឆ្នោតគ្រប់រូបឱ្យទៅមើលឈ្មោះ និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួនតាមទីតាំងដែលបានបិទផ្សាយ។

បន្ទាប់ពីរយៈពេល ១០ (ដប់) ថ្ងៃនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងក្នុងករណីគ្មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ណាមួយទេនោះ កបឃ.ស ត្រូវធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របច្បាប់ មានសិទ្ធិស្នើសុំបញ្ជីបោះឆ្នោតដំបូងច្បាប់ថតចម្លង ឬ PDF File បានដោយបង់ថ្លៃត្រឹមតម្លៃផលិត។

## VIII. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

ជនណាក៏ដោយមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងទៅ កបឃ.ស ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

| ពាក្យបណ្តឹងតវ៉ា អាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់អំពីករណីដូចខាងក្រោម | ពាក្យបណ្តឹងជំទាស់ អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង |
|---|---|
| - មិនឃើញមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង (មានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ឬបង្កាន់ដៃទទួលការប្តូរការិយាល័យក្នុងឃុំ សង្កាត់ជាភស្តុតាង)។<br>- មានឈ្មោះ ប៉ុន្តែឈ្មោះនោះនៅក្នុងការិយាល័យផ្សេងទៅវិញ។<br>- មានឈ្មោះ ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ព័ន្ធមានភាពមិនច្បាស់លាស់ ឬមិនត្រឹមត្រូវ។<br>- ឃើញឈ្មោះដែរ តែឈ្មោះនោះស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់។ | - មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង តែជននោះគ្មានសិទ្ធិចុះឈ្មោះ៖<br>ං មិនមានសញ្ជាតិខ្មែរ។<br>ං មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោតស្របតាមច្បាប់។<br>ං មិនមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់។<br>ං ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច។<br>- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាង០១(មួយ)កន្លែង។ |

១. ការដាក់ ការទទួល និងការដោះស្រាយបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់នៅ កបឃ.ស

| ក. ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ | |
|---|---|
| **ការប្តឹងតវ៉ា** | **ការប្តឹងជំទាស់** |
| ការប្តឹងតវ៉ាត្រូវធ្វើក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ | ការប្តឹងជំទាស់ត្រូវធ្វើក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។ |

## ខ. ការទទួលពាក្យបណ្តឹង

<table>
<tr><th>ពាក្យបណ្តឹងតវ៉ា</th><th>ពាក្យបណ្តឹងជំទាស់</th></tr>
<tr><td>
- នៅពេលទទួលពាក្យបណ្តឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍៖<br>
 ∘ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬ/និងតំណាង<br>
 ∘ កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពអំឡុងពេលកំណត់ ១០ (ដប់) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។<br>
- ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុនោះ។ ក្នុងករណី អ្នកប្តឹងមិនព្រមផ្តិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។<br>
- ទ.១២០២ ចំនួន ០៣ (បី) ច្បាប់ចុះកាលបរិច្ឆេទ ពេលវេលាទទួល កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងប្រជុំសម្រេច<br>
ទ.១២០២=០៣ច្បាប់<br>
 - ០១ច្បាប់ ជូនអ្នកប្តឹងតវ៉ា ឬតំណាង<br>
 - ០១ច្បាប់ បិទផ្សាយនៅសាលាឃុំសង្កាត់<br>
 - ០១ច្បាប់ រក្សាទុកជាឯកសារ<br>
- ពាក្យបណ្តឹងដែលគោរពអំឡុងពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន និងសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។<br>
- អ្នកប្តឹងបង្ហាញឯកសារភស្តុតាង ឬសាក្សី។
</td><td>
- នៅពេលទទួលពាក្យបណ្តឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍៖<br>
 ∘ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬ/និងតំណាង<br>
 ∘ កម្មវត្ថុនៃពាក្យបណ្តឹង និងការគោរពអំឡុងពេលកំណត់ ១០ (ដប់) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។<br>
- ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុនោះ។ ក្នុងករណី អ្នកប្តឹងមិនព្រមផ្តិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនោះ។<br>
- ទ.១២០២ ចំនួន ០៤ (បួន) ច្បាប់ ចុះកាលបរិច្ឆេទ ពេលវេលាទទួល កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងប្រជុំសម្រេច<br>
ទ.១២០២=០៤ច្បាប់<br>
 - ០១ច្បាប់ ជូនអ្នកប្តឹងជំទាស់ ឬតំណាង<br>
 - ០១ច្បាប់ ជូនអ្នកត្រូវគេប្តឹង<br>
 - ០១ច្បាប់ បិទផ្សាយនៅសាលាឃុំសង្កាត់<br>
 - ០១ច្បាប់ ទុកប្រើប្រាស់ក្នុងពេលប្រជុំសម្រេច<br>
- ពាក្យបណ្តឹងដែលគោរពអំឡុងពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន និងសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។<br>
- ជូនដំណឹងទៅអ្នកដែលត្រូវគេប្តឹង។<br>
- អ្នកប្តឹងជំទាស់ត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សី។<br>
- អ្នកត្រូវគេប្តឹងជំទាស់មានសិទ្ធិបដិសេធដោយបង្ហាញឯកសារ។
</td></tr>
</table>

## គ. ការប្រជុំសម្រេចជាសាធារណៈ: (រយៈពេល ០៣ ថ្ងៃ)

កបឃ.ស ត្រូវបើកការប្រជុំសម្រេចជាសាធារណៈសម្រេចបដិសេធ ឬយល់ព្រមលើបណ្តឹង ដោយធ្វើកំណត់ហេតុប្រជុំសម្រេច។

### គ.១. ករណីបដិសេធ

| បណ្តឹងតវ៉ា | បណ្តឹងជំទាស់ |
|---|---|
| - ស្រង់សេចក្តីសម្រេចបដិសេធដាក់ក្នុង ទ.១២០៣ ចំនួន ០៣ (បី) ច្បាប់ បញ្ជាក់មូលហេតុ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់។<br>ទ.១២០៣=០៣ច្បាប់ {<br>- ០១ច្បាប់ ជូនអ្នកប្តឹងតវ៉ា ឬតំណាង<br>- ០១ច្បាប់ ជូនគ.ជ.ប<br>- ០១ច្បាប់ រក្សាទុកជាឯកសារ<br>- ជូន ទ.១២០២ = ០៣ (បី) ច្បាប់ដល់អ្នកប្តឹង (បើសុំ) ជម្រាបគាត់ឱ្យបំពេញចំនួន ០៣ (បី) ច្បាប់ ⇨ រួចយកទៅដាក់នៅ គ.ជ.ប យ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។ | - ស្រង់សេចក្តីសម្រេចបដិសេធដាក់ក្នុង ទ.១២០៣ ចំនួន ០៤ (បួន) ច្បាប់បញ្ជាក់មូលហេតុ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់។<br>ទ.១២០៣=០៤ច្បាប់ {<br>- ០១ច្បាប់ ជូនអ្នកប្តឹងជំទាស់ឬតំណាង<br>- ០១ច្បាប់ ជូនអ្នកត្រូវគេប្តឹង<br>- ០១ច្បាប់ ជូនគ.ជ.ប<br>- ០១ច្បាប់ ទុកជាឯកសារ<br>- ជូន ទ.១២០២ = ០៤ (បួន) ច្បាប់ដល់អ្នកប្តឹង (បើសុំ) ជម្រាបគាត់ឱ្យបំពេញចំនួន ០៤ (បួន) ច្បាប់ ⇨ រួចយកទៅដាក់នៅ គ.ជ.ប យ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។ |

### គ.២. ករណីយល់ព្រម

| បណ្តឹងតវ៉ា | បណ្តឹងជំទាស់ |
|---|---|
| - ស្រង់សេចក្តីសម្រេចយល់ព្រមដាក់ក្នុង ទ.១២០៣ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់។<br>ទ.១២០៣=០៣ច្បាប់ {<br>- ០១ច្បាប់ ជូនអ្នកប្តឹងតវ៉ា ឬតំណាង<br>- ០១ច្បាប់ ជូនគ.ជ.ប<br>- ០១ច្បាប់ រក្សាទុកជាឯកសារ<br>- កបឃ.ស អនុវត្តតាមសេចក្តីសម្រេច រួចកត់ត្រាទុកក្នុង ទ.១០២០ ដើម្បីត្រៀមធ្វើរបាយការណ៍សរុបបញ្ជូនមក ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត នៅពេលបញ្ចប់ការដោះស្រាយបណ្តឹង។ | - ស្រង់សេចក្តីសម្រេចយល់ព្រមដាក់ក្នុង ទ.១២០៣ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់។<br>ទ.១២០៣=០៤ច្បាប់ {<br>- ០១ច្បាប់ ជូនអ្នកប្តឹងជំទាស់ឬតំណាង<br>- ០១ច្បាប់ ជូនអ្នកត្រូវគេប្តឹង<br>- ០១ច្បាប់ ជូនគ.ជ.ប<br>- ០១ច្បាប់ ទុកជាឯកសារ<br>- ជូន ទ.១២០២ ចំនួន ០៤ (បួន) ច្បាប់ដល់អ្នកត្រូវគេប្តឹង (បើសុំ) ជម្រាបគាត់ឱ្យបំពេញ រួចយកមកដាក់នៅ គ.ជ.ប រយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃទទួល ទ.១២០៣<br>- កបឃ.ស ស្រង់កត់ត្រាទុកក្នុង ទ.១០២០ ត្រៀមធ្វើរបាយការណ៍សរុប រួចបញ្ជូនមក ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត នៅពេលបញ្ចប់ការដោះស្រាយបណ្តឹង។ |

## ២. ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងនៅ គ.ជ.ប

អ្នកប្ដឹងតវ៉ា អ្នកប្ដឹងជំទាស់ ឬអ្នកត្រូវគេប្ដឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។ អ្នកប្ដឹងត្រូវបំពេញ ទ.១២០២ ចំនួន ០៣ (បី) ច្បាប់ (ករណីប្ដឹងតវ៉ា) ឬចំនួន ០៤ (បួន) ច្បាប់ (ករណីប្ដឹងជំទាស់)។

គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្ដឹងក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

## ៣. ការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

អ្នកប្ដឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្ដឹងតវ៉ា ឬប្ដឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមលើបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្ដីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

## ៤. ការបំពេញរបាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០)

កបឃ.ស ត្រូវបំពេញរបាយការណ៍ស្ដីពីសេចក្ដីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ (ទ.១០២០) ចំនួន ០៣ (បី) ច្បាប់ ដែលមានតារាងជូនភ្ជាប់ជាមួយ និងឯកសារបញ្ជាក់ផ្ញើជូន ន. គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត តាមរយៈ លធ.ខប។

កបឃ.ស ត្រូវបំពេញទម្រង់បែបបទនេះនៅពេលបញ្ចប់ការដោះស្រាយបណ្ដឹងនៅថ្នាក់ខ្លួន ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង។ ទ.១០២០ ប្រើប្រាស់ដូចខាងក្រោម៖

ទ.១០២០ =០៣ ច្បាប់
- ០២ ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប
- ០១ ច្បាប់ រក្សាទុកជាឯកសារនៅឃុំ សង្កាត់។

## ៩. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយបណ្ដឹងក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ក្នុងការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

### ក. ករណីពាក្យបណ្ដឹងតវ៉ា



## ខ. ករណីពាក្យបណ្តឹងជំទាស់



### ៦. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ

នៅពេលដែលបណ្ដឹងតវ៉ា ឬ/និងបណ្ដឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូងត្រូវបានដោះស្រាយចប់ជាស្ថាពរ គ.ជ.ប ត្រូវបោះពុម្ព និងចាត់បញ្ជូនបញ្ជីបោះឆ្នោតផ្លូវការទៅ លធ.ខប ចំនួន ០១ (មួយ) ច្បាប់ និងសាលាឃុំ សង្កាត់ចំនួន ០១ (មួយ) ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ។

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិស្នើសុំពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតនេះបាននៅតាមសាលាឃុំ សង្កាត់ ឬ លធ.ខប។

គណបក្សនយោបាយ ដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតផ្លូវការច្បាប់ថតចម្លងបានដោយបង់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។

គ.ជ.ប ត្រូវបង្ហោះបញ្ជីបោះឆ្នោតផ្លូវការនៅលើគេហទំព័ររបស់ខ្លួន (www.voterlist.org.kh) ដោយត្រូវធានាការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពរបស់បុគ្គល។

### ៧. ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបាត់បង់លក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងការស្រង់ឈ្មោះប្រជាពលរដ្ឋខ្មែរដែលត្រូវបំពេញលក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅក្រោយពេល គ.ជ.ប ផ្ដល់សុពលភាពលើបញ្ជីបោះឆ្នោត

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្ដល់សុពលភាពរួចហើយ គ.ជ.ប ត្រូវធ្វើការស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលបាត់បង់លក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងប្រជាពលរដ្ឋខ្មែរដែលត្រូវបំពេញលក្ខខណ្ឌ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត សម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតប្រចាំឆ្នាំ តាមឃុំ សង្កាត់នីមួយៗ។ អនុលោមតាមមាត្រា ៥១ នៃ ច.ប.ត.រ ស្មៀនឃុំ សង្កាត់ ត្រូវបំពេញតួនាទីខាងលើនេះដោយសហការជាមួយ លធ.ខប។

ស្មៀនឃុំ សង្កាត់ និងកបឃ.ស ត្រូវស្រង់ឈ្មោះ៖

- អ្នកបោះឆ្នោតដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ទៅឃុំ សង្កាត់ផ្សេងហើយមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ ដាក់ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតចុងក្រោយក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ (ទ.១០២៥ ) ហើយត្រូវថតចម្លងបញ្ជីនេះជូន គ.ជ.ប តាមរយៈ លធ.ខប រៀងរាល់ ០២ (ពីរ) ខែម្ដង។
- ប្រជាពលរដ្ឋខ្មែរដែលមិនទាន់បានចុះឈ្មោះពីមុនមក ឬ/និងដែលទើបដល់អាយុត្រូវបោះឆ្នោត ឬ/និងបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីដាក់ក្នុងបញ្ជីឈ្មោះអ្នកមានសិទ្ធិបោះឆ្នោត (ទ.១០២៧) ដែលនឹងត្រូវអញ្ជើញចុះឈ្មោះបោះឆ្នោតឆ្នាំ

២០១៧ ហើយត្រូវថតចម្លងបញ្ជីនេះជូន គ.ជ.ប តាមរយៈ លធ.ឧប រៀងរាល់ ០២ (ពីរ) ខែម្តង។

ក្នុងអំឡុងរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ គ.ជ.ប តាមរយៈ លធ.ឧប ត្រូវសហការជាមួយក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ដើម្បីលុបឈ្មោះអ្នកបោះឆ្នោតដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ទៅឃុំ សង្កាត់ផ្សេង ចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ឬ/និងជូនដំណឹងដល់ប្រជាពលរដ្ឋខ្មែរ ដែលមិនទាន់បានចុះឈ្មោះពីមុនមក ឬ/និងដែលទើបដល់អាយុត្រូវបោះឆ្នោត ឬ/និងបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ឱ្យមកចុះឈ្មោះបោះឆ្នោត ដោយត្រូវបំពេញលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។

# តារាងសង្ខេបទម្រង់បែបបទដែលត្រូវប្រើប្រាស់តាមលំដាប់ថ្នាក់
# សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

| ក្រុមចុះឈ្មោះបោះឆ្នោត | | ក្រុមប្រឹក្សាឃុំ សង្កាត់ | | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | |
|---|---|---|---|---|---|
| លេខទម្រង់ | ខ្លឹមសារ | លេខទម្រង់ | ខ្លឹមសារ | លេខទម្រង់ | ខ្លឹមសារ |
| ១០០៩ | សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត | ១០០១ | កិច្ចសន្យាបម្រើការងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត | ១០១៤ | លិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការ បញ្ជូនស្បោង «គ» ដោយ លធ.ខប |
| ១០១១ | របាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត | ១០០៦ | តារាងប្រាក់កម្រៃមន្ត្រីចុះឈ្មោះបោះឆ្នោត | ១០១៥ | លិខិតបញ្ជាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត ដែលត្រូវបានផ្គត់ផ្គង់បន្ថែម |
| ១០១២ | របាយការណ៍សរុបស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ | ១០០៧ | ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ១១០៧ | លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ ចុះឈ្មោះបោះឆ្នោត |
| ១០១៣ | លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះ | ១០២០ | របាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ គបឃ.សកែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ | | |
| ១០២១ | របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត | ១០២៤ | កំណត់ហេតុវាយតម្លៃសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត | | |
| ១០២២ | ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត | ១១០៧ | លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត | | |
| ១០២៨ | បង្កាន់ដៃទទួលការប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ | ១២០២ | ពាក្យបណ្តឹង | | |
| ១០២៩ | របាយការណ៍ស្តីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ | ១២០៣ | សម្រង់សេចក្តីសម្រេច | | |
| ១១០៧ | លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត | | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត | | |
| ១២០២ | ពាក្យបណ្តឹង | | លិខិតបញ្ជាក់ទីលំនៅ | | |

## ភារកិច្ចសង្ខេបរបស់ក្រុមចុះឈ្មោះបោះឆ្នោត និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រចាំការ សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

### កម្លាំងរក្សាសណ្តាប់ធ្នាប់

- ទទួលភារកិច្ចសម្រួលសណ្តាប់ធ្នាប់សុំឱ្យអ្នកសុំចុះឈ្មោះបង្ហាញឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត។
- សម្រួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ០៣ (បី) នាក់ ឬច្រើនជាងនេះតាមចំនួនការីកុំព្យូទ័រ។
- ផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ឬស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាពចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។
- អនុញ្ញាតឱ្យជំនួយជានីតិជនម្នាក់ជូនដំណើរជនមានពិការភាពដែលមិនអាចចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។
- រាយការណ៍ជាបន្ទាន់ជូន កបឃ.ស ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ ឬច្រើននាក់ ដើម្បីមានវិធានការស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច។

### សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រចាំការ

- ត្រូវដឹកនាំ ក.ច.ប ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត និង ប.ន.ប.ថ
- ប្រចាំការពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោត និងរាយការណ៍ជាប្រចាំជូនក្រុមប្រឹក្សាឃុំ សង្កាត់ អំពីភាពជឿនលឿននៃការចុះឈ្មោះបោះឆ្នោត។
- ចាត់ចែងឱ្យមានកម្លាំងរក្សាសណ្តាប់ធ្នាប់តាមលទ្ធភាព និងការចាំបាច់សម្រាប់សម្រួលដល់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។ ការចាត់ចែង ប្រើប្រាស់កម្លាំងរក្សាសណ្តាប់ធ្នាប់នេះស្ថិតក្នុងសមត្ថកិច្ច និងបន្ទុកដោះស្រាយរបស់ កបឃ.ស
- ចាត់វិធានការសមស្របដើម្បីធានាថា រាល់កិច្ចប្រតិបត្តិការទាក់ទងដល់ការចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅក្នុង
- បរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង។ ចាត់ចែងដោះស្រាយឱ្យមានអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងមានសមត្ថកិច្ច តាមសំណើរបស់ ក.ច.ប ក្នុងករណីដែលមានជនណាបង្កការអុកឡុករំខាន គំរាមកំហែង ឬប្រព្រឹត្តអំពើល្មើសច្បាប់ សំដៅបង្អាក់ដំណាក់កាលណាមួយនៃការចុះឈ្មោះបោះឆ្នោត។

### ប្រធានក្រុមចុះឈ្មោះបោះឆ្នោត

- សម្ភាសអ្នកសុំចុះឈ្មោះបោះឆ្នោតនិងសាកសួរព័ត៌មានគាត់ថា៖
  - តើមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតឬទេ ?
  - តើគាត់បានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ ឬនៅ ?
- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងមិនទាន់បានចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ ប្រធាន ក.ច.ប ត្រូវពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះដូចខាងក្រោម៖
  - ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
  - មានអាយុ ១៨ឆ្នាំ ឡើងទៅគិតដល់ថ្ងៃបោះឆ្នោត (កើតមុន ឬត្រឹមថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៩)
  - មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន ក.ច.ប ដើម្បីបន្តនីតិវិធីចុះឈ្មោះបោះឆ្នោតតាមជំហានបន្តបន្ទាប់ (ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញគ្រប់លក្ខខណ្ឌកំណត់)។
- មានសិទ្ធិសម្រេចក្នុងការប្តូរការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់
- បំពេញសម្រង់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់ពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះមិនបានបំពេញ។
- ធ្វើការកត់ត្រាចូលក្នុងរបាយការណ៍ជូន គ.ជ.ប ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន។
- ផ្តល់សិទ្ធិ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ដើម្បីរក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតនោះទៅក្នុងប្រព័ន្ធកុំព្យូទ័រ។

## ភារកិច្ចសង្ខេបរបស់ក្រុមចុះឈ្មោះបោះឆ្នោត និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រចាំការ សម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

### អនុប្រធាន គ.ច.ប ឬសមាជិកជួយអនុប្រធាន

- សួរទីលំនៅ នៅភូមិណាដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោតក្នុងភូមិនោះ។
- បំពេញ ទ.១០២២ ទ.១០២៨ និងគូសធិកសម្គាល់ក្នុង ទ.១០២២ (ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឆ្នាំ២០១៦ ក្នុងឃុំ សង្កាត់ផ្សេង)។
- ប្រគល់ អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ និងបង្កាន់ដៃ ទ.១០២២ ឬទ.១០២៨ ទៅការីកុំព្យូទ័រ និងជម្រាបអ្នកសុំចុះឈ្មោះនោះឱ្យទៅជួបការីកុំព្យូទ័រ។

### ការីកុំព្យូទ័រ ឬសមាជិក គ.ច.ប ដែលជាការីកុំព្យូទ័រ ក្នុងឃុំ សង្កាត់ដែលមានការីកុំព្យូទ័រលើសពីម្នាក់

- កត់ត្រាទិន្នន័យអ្នកសុំចុះឈ្មោះទៅក្នុងប្រព័ន្ធកុំព្យូទ័រដោយផ្អែកតាម អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម៖
  - ជ្រើសយកឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត តាម ទ.១០២២ ឬទ.១០២៨
  - ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតជាមុន បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាងសម្រាប់ដំណើរការកម្មវិធី។ ចំពោះអ្នកពិការដៃម្ខាង ឬទាំងសងខាង ឬគ្មានស្នាមម្រាមដៃ ស្នើសុំប្រធាន គ.ច.ប ដើម្បីដំណើរការកម្មវិធី
  - ថត អ.ខ ឬ ឯ.អ
  - បញ្ចូលលេខ អ.ខ ឬ ឯ.អ
  - ជ្រើសរើសយកប្រភេទឯកសារសម្រាប់ប្រើចុះឈ្មោះបោះឆ្នោត (អ.ខ ឬ ឯ.អ)
  - បញ្ចូលអត្តលេខអ្នកសុំចុះឈ្មោះដែលមាននៅក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២)
  - បញ្ចូលនាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត
  - បញ្ចូលលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់របស់សាមីខ្លួន។
- ផ្ទេរឈ្មោះ និងទិន្នន័យអ្នកសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទៅការិយាល័យបោះឆ្នោតថ្មីក្នុងភូមិដែលគាត់រស់នៅ តាមការកំណត់របស់អនុប្រធាន គ.ច.ប។
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើម៉ាស៊ីនស្កេន ដើម្បីយកស្នាមមេដៃសាមីខ្លួនទាំងសងខាងបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រដោយត្រូវស្កេនមេដៃម្ខាងៗចំនួន ០៤ ដង និងត្រូវយកស្នាមមេដៃឆ្វេងជាមុន។ ក្នុងករណីអ្នកសុំចុះឈ្មោះពិការមេដៃណាមួយ ឬទាំងសងខាងត្រូវយកស្នាមម្រាមដៃបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះពិការដៃម្ខាងត្រូវយកស្នាមមេដៃម្ខាងដែលមាន។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបានត្រូវធ្វើការកត់ត្រាចូលក្នុងរបាយការណ៍ជូន គ.ជ.ប។
- ថតរូបចំពីមុខ និងថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន)។ ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ការីកុំព្យូទ័រត្រូវថតយកដូចខាងក្រោម៖
  - ថតយកសន្លឹកទី ២ ដែលបញ្ជាក់ពីលំនៅឋាន សម្រាប់សៀវភៅគ្រួសារ
  - ថតយកសន្លឹកទី ១ ដែលបញ្ជាក់ពីលំនៅឋាន សម្រាប់សៀវភៅស្នាក់នៅ
  - ថតយកទម្រង់ទាំងមូល សម្រាប់លិខិតបញ្ជាក់ទីលំនៅ។
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យគាត់ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ។ ករណីអ្នកសុំចុះឈ្មោះមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យរបស់គាត់។
- រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ស្នើសុំប្រធាន គ.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងប្រព័ន្ធកុំព្យូទ័រ។
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និង អ.ខ ឬ ឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។ បញ្ជូនទិន្នន័យអ្នកបោះឆ្នោតទៅ ន.គ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតម្តង ១០ នាក់ ឬតាមលទ្ធភាពដែលអាចធ្វើបាន។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

# ប្រតិទិននៃការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៦

| ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការចែកលិខិតអញ្ជើញអ្នកចុះឈ្មោះអ្នកបោះឆ្នោត | ថ្ងៃទី០១-៣១ ខែសីហា ឆ្នាំ២០១៦ |
| ការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ | ថ្ងៃទី០១.សីហា.១៦ - ០២.កុម្ភៈ.១៧ |
| ការចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ | ថ្ងៃទី០១.សីហា.១៦ - ០៩.កុម្ភៈ.១៧ |
| ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ថ្ងៃទី២៥.សីហា.១៦ - ០២.កុម្ភៈ.១៧ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យចុះឈ្មោះ និងការិយាល័យបោះឆ្នោត | ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ |
| ការចាប់ផ្តើមចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ |
| ការបញ្ចប់ការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់ | ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ |
| ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈ ពេល ០៣ថ្ងៃ | ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ានឹងសេចក្តីសម្រេចបដិសេធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈ ពេល ០៥ថ្ងៃ | ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ានឹងសេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ (ថ្ងៃចុងក្រោយ) |
| ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ទូទាំងប្រទេស | ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ |
| ការប្តឹងតវ៉ា ឬប្តឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូងទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ០៣ថ្ងៃ | ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការប្តឹងតវ៉ា ឬប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ០៥ថ្ងៃ | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៧ (ថ្ងៃចុងក្រោយ) |
| ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតដោយ គ.ជ.ប | ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៧ |

បោះពុម្ពដោយ គ.ជ.ប

ឆ្នាំ២០១៦